សារព័ត៌មាន ខ្មែរផុស្ត ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Websit : khmerpost.us
Advertising: 978-656-8141/ Hotline news: 1 (267) 253-3947

មាតិការរឿង Vol 07 Issue 132-June 22nd- July 12th. 2013 ទំព័រ

១–៨មិនា ១៩៦៩ ជាដើមចម..........................០៣
២–ខ្មែរកជាតិនិយម..........................................០៤
៣–អ្នកក្រ និងអ្នកមានស្រុកខ្មែរ..........................០៥
៤–បាតុកម្មប្រឆាំងលោក កឹម សុខា...................០៥
៥– The Cambodia daily.....................០៦
៦–ក្តួបបលរីតណេសរាយការណ៍ពីបរិស្ថាន...........០៨
៧–វិស្វកម្មក្នុងចិត្តមនុស្ស.................................១៥
៨–ហោរាសាស្ត្រប្រចាំឆ្នាំ...............................១៧

New Office: Tel: (978) 677-7163 Tel-Fax: (978) 677-7092
45 Merrimack St. Suite 218A Lowell, MA 01852

## វិចារណកថា

## ជំលោះបងប្អូនរួមឈាម វត្តសូរិយារង្សីដល់ណាហើយ?

**ដោយៈ បញ្ញាសីលា**

អ្នកអានមួយចំនួនមិនអស់ចិត្តសោះពីរឿងវិវាទរវាងបងប្អូនរួមឈាមយើងដែលជាអ្នកឈឺចាប់ច្រើនហើយ ដោយការប្រេះឆាបែកបាក់បង្ហូរឈាមបងប្អូនឯងនេះវាបណ្តាលឱ្យរត់ចោលស្រុក,ចោលភូមិ,កេរ្តិ៍អាករ៍,ចោលម៉ែចោលឪប្រពន្ធកូនសាត់ព្រាត់ររាត់ររាយមកស្រុកគេធ្វើការស៊ីឈ្នួលនឿយហត់,អនាគតគ្មានអីជាមោទនភាពសោះនេះ តើយើងទាំងអស់គ្នារៀនបានអី ទេម្នាក់ៗ? ចោលស្រុកឱ្យសត្រូវចូលមកធ្វើម្ចាស់ជិះជាន់បងប្អូនដែលរត់មិនរួចក្លាយជាគោក្របីស្រេចតែគេបំពាក់ខ្នោះឃ្នៀង,អូសនង្គ័លទាញរទេះអូសសាឡី,អូសគាវ ។ ខ្លួនមានសំណាងជាងរត់យកតែ "អាយ៉ូស" មកដល់ស្រុកសុខសប្បាយដែលគេបានរៀបចំច្បាប់ស្រេចស្រួលបួលហើយនេះ តើរៀនបានអ្វីខ្លះឬទេ? កុំភ្លេចឱ្យសោះថាកម្ពុជា ក្រោមក្តី,ព្រះរាជាណាចក្រកម្ពុជាក្តីមានវាសនាមិនខុសគ្នាទេ, យើងទាំងអស់គ្នាមកដល់នេះ **តទៅទំព័រទី ១៨**

# សិស្សសាលា Moody និង Lyncoln ទទួលសញ្ញាប័ត្រពីការរៀន "លុយឆ្លាត"

**ឡូវែលៈ** ជាលើកដំបូងបង្អស់នៅរដ្ឋម៉ាសាឈូសែតដែលកុមារាកុមារីនៅសាលាបឋមសិក្សា Moody និង Lincoln ទទួលសញ្ញាប័ត្រសិក្សាទាំងវិជ្ជាសន្សំលុយរៀបរៀងដោយធនាគារ Washington Saving ។ កម្មវិធីនេះបានផ្តួចផ្តើមផ្តល់ជូនដល់កុមារាកុមារីនៅសាលារៀនដែល កាលពីមុនជាភារៈកិច្ចរបស់មាតាបិតាក្នុងការបង្ហាត់បង្ហាញកូនចៅឱ្យស្គាល់ **តទៅទំព័រទី ១២**



## ខ្មែរក្រោមក្នុងជម្លោះដ៏ធំផងមួយ

**ខ្មែរផុសស.រ.អា**

**ហ្វីឡាដែលហ្វៀៈ** ជម្លោះយ៉ាងចេញមុខមួយបានផ្ទុះឡើងនៅវត្តសុរិយារង្សីរវាងសហគមន៍មានវត្តសុរិយារង្សីជាឧបករណ៍ សាមគ្គីនេះបានប្រែជាប្រេះស្រាំគួរឱ្យស្តាយ ។

"ខ្មែរក្រោម"ជាឧទ្ទេសនាមនៃជនជាតិកម្ពុជា



ភិក្ខុ យេង តូច ភិក្ខុ អៀង ភិរុណ

ខ្មែរក្រោមនៃ "សមាគមខ្មែរកម្ពុជាក្រោម KKKA" និង"សហព័ន្ធខ្មែរកម្ពុជាក្រោម KKF" ដែលតាំងពីដើមមកក្រុមទាំងពីរតែងតែជាគំរូសម្រាប់ខ្មែរទូទៅនៃការចុះសម្រុងសាមគ្គីគ្នា ឥឡូវនេះដោយមួយក្រុមមានដើមកំណើត និងរស់នៅក្នុងការគ្រប់គ្រងនៃប្រទេសវៀតណាមខាងត្បូងតែចាក់ឫសគល់ជាគ្រាប់ពូជពង្សខ្មែរជាមួយវប្បធម៌ជាតិដើមរបស់ខ្លួនយ៉ាង **តទៅទំព័រទី ០៧**

## "ប្រដាល់សេរីខ្មែរ" នៅលីន រៀបចំចូលប្រកួតឆ្នាំ២០១៤

**ដោយ : ពិន សំខុន**

●●●លោកគ្រូ សារឿម ភួង គ្រូបង្ហាត់កីឡាប្រដាល់សេរីខ្មែរនៅទីក្រុងលីនរដ្ឋម៉ាសាឈូសែតបាននិយាយថា "លោកកំពុងបង្ហាត់ហ្វឹកហ្វឺនកូនសិស្សប្រដាល់សេរីស្ត្រី និងបុរស ដើម្បីឱ្យអាចចូលរួមប្រកួតសហព័ន្ធកីឡាប្រដាល់សេរីឆ្នាំ២០១៤ សារជាថ្មី" ។



នៅសាលាប្រដាល់សេរីរបស់លោកគ្រូសារឿន មានទំហំតូចតែយើងបានឃើញសិស្សស្រីប្រុសខ្មែរ និងសាសន៍ផ្សេងៗចំនួន២០នាក់បានបង្ហាញការគោរពវិន័យខ្ពស់ខិតខំស្ទាប់ដំបូន្មានខ្លះហាត់កំដៅប្រាណ ខ្លះទៀតហាត់វាយ ឬទាត់បាវយ៉ាងស្ទៀមស្ទាត់ ។ គ្រូបង្ហាត់ក្នុងអាយុ៤១ឆ្នាំ លោកធ្លាប់បានដឹកនាំសិស្សទៅចូលប្រកួតហើយទទួលបានកិត្តិយសដោយសិស្សសាលា

**តទៅទំព័រទី ០៨**

# GLOBAL REALTY NETWORK LLC

*Integrity, Exceptional Service, Outstanding Results*

**Business For Sale FROZEN YOGURT**

Asking Price: **$44,900.00**



Be your own boss and create jobs for other family members by owning this well established, popular Frozen Yogurt with loyal customers, great income, and visible in a stand alone building along with other businesses. There are additional space on the second and third floor for storage and other use. Please call today!



**Paul-Rathal Yem, CBR/CDPE/AREAA**
**HUD Approved Broker**
Global Realty Network, LLC
16 Pine Street, Suite 13, Lowell, MA 01851
**(800) 494-2400 Toll Free**
**(888) 789-0954 Fax -**
**(617) 459-3000 Cell**
GlobalRealtyNetwork.com

# ភោជនីយដ្ឋាន សុភមង្គលថ្មី

"New Happiness Restaurant"
Open from 7:30AM-9:00PM




ទើបបើកថ្មីនៅឡូវែល
ម្ចាស់ថ្មី, ហាងខ្មែរ, ម្ហូបខ្មែរពិត។




**ម្ហូបដែលភ្ញៀវតែងចូលចិត្តពិសារ**

**ពេលព្រឹក :** គុយទាវ $5.95
**ម្ហូបពិសេស :** មីទាផាកឡូវ Meetea phaklov $7.95
**ពេលថ្ងៃ និងល្ងាច:** សម្លកកូរ , សម្លម្ជូរគ្រឿង,សម្លម្ជូរសៀមរាប, $11.95
គ្រឿងសមុទ្រឆ្អិតស្រួយ, ពោះវៀនខស្ពៃជូ,
សម្លរផ្អាំងភ្លើង,គ្រឿងក្លែមសាមគ្គី

*និងមានម្ហូបច្រើនមុខទៀត ធ្វើដោយចុងភៅល្បីឈ្មោះ ដែលមានជំនាញជាង៣០ឆ្នាំហើយ នៅភ្នំពេញ និងសៀមរាប*


Som-law Ka kor


Cha knyei | Som-law ma-ju tro koun | Mee Ka Tang | Roasted pork

អាស័យដ្ឋាន: 6 Branch Street Lowell. MA 01851
ទូរស័ព្ទ : **(978)454-4727**

# **Now I have someone** to drive me to the doctor.

With **UnitedHealthcare® Senior Care Options (HMO SNP),** you'll have a Personal Care Manager. Your Personal Care Manager will help you coordinate the services you may need, like rides to doctor appointments, and answer questions about staying healthy and more. It's your doctor, hospital and prescription drug coverage and independent living support in one simple plan.

- $0 copay for eyewear (up to $125 annually)
- $0 copay for dental fillings and dentures
- $0 copay for rides to doctor appointments
- $0 copay for all prescribed medications

Get more benefits in one plan at no cost to you.

Find out more today.
Call **1-888-727-8595,** TTY: **711,** or go to **UHCCommunityPlan.com.**

UnitedHealthcare®
Community Plan

UnitedHealthcare Senior Care Options (UnitedHealthcare SCO) is a voluntary program available to people who are 65 and older. UnitedHealthcare SCO is a Coordinated Care plan with a Medicare Advantage contract and a contract with the Commonwealth of Massachusetts Medicaid program. The benefit information provided herein is a brief summary, not a comprehensive description of benefits. For more information contact the plan.

MASCO 120213_173411
H2226_120213_173411 CMS Accepted

CST2965_240590

# ១៨ មិនា ១៩៦៩ ជាដើមចមនៃវិបត្តិសុខភាពរបស់ពលរដ្ឋខ្មែរអាមេរិកាំង

តពីលេខមុន



សេងលី គួង

ព្រឹត្តិការណ៍នយោបាយការទម្លាក់គ្រាប់បែកការប្រល័យពូជសាសន៍ សង្គ្រាមស៊ីវិល និងវិបត្តិមនុស្សធម៌ក្នុងជំរុំជនភៀសខ្លួននានាមិនត្រឹមតែធ្វើឱ្យមនុស្សរាប់លាននាក់ស្លាប់ពិការ និងកំព្រាឪពុកម្តាយប៉ុណ្ណោះទេ វាបាននិងកំពុងបន្សល់ទុកនូវផលវិបាកផ្នែកសុខភាពផ្លូវកាយ និងផ្លូវចិត្តដល់ប្រជាជនកម្ពុជារាប់លាននាក់រួមទាំងពលរដ្ឋខ្មែរអាមេរិកាំងជាង១៣០.០០០នាក់មកដល់សព្វថ្ងៃនេះ។

**រូបទី២:** Cambodian American Report Dramatically Higher Rates (%) of PTSD, Depression, Hypertension, Diabetes, Stroke than the General Population




Sources: US data (age 18+) from CDC-BRFSS Survey

ពលរដ្ឋខ្មែរអាមេរិកាំងដែលសេសសល់ជីវិតពីរបបវាលពិឃាតមានសុខភាពលំបាកលំបិនខ្លាំងបើប្រៀបធៀបនឹងពលរដ្ឋអាមេរិកាំងទូទៅ(រូបទី២)។ សមាគមគាំទ្រសុខភាពខ្មែរបានស្ទង់មតិពលរដ្ឋខ្មែរអាមេរិកាំងដែលមានអាយុ៣៥ឡើង ដែលរស់នៅភាគខាងលិចនៃរដ្ឋម៉ាស្សាឈូសេត្ស និងរដ្ឋកានិកតិកិតចំនួន១៤០នាក់ ក្នុងឆ្នាំ២០១១។

អ្នកចូលរួម៦៧%បានត្រូវប្រាប់ដោយគ្រូពេទ្យរបស់ខ្លួនថា មានជំងឺរន្ធត់ចិត្ត (PTSD), 65% មានជំងឺពិបាកចិត្ត (Depression), 40.7% មានជំងឺលើសឈាម (Hypertension), 27% មានជំងឺទឹកនោមផ្អែម(Diabetes) និង8%មានជំងឺដាច់សរសៃឈាមខួរក្បាល (Stroke)។

**រូបទី៣:** Cambodian Americans have more chronic disease at younger age than other Americans




ខ្មែរអាមេរិកាំងមានជំងឺរ៉ាំរ៉ៃច្រើនជាង និងក្នុងវ័យក្មេងជាងពលរដ្ឋអាមេរិកាំងឯទៀត។ ការសិក្សាក៏បានបង្ហាញថា ៥០% នៃអ្នកចូលរួមស្ទង់មតិមានជំងឺរ៉ាំរ៉ៃយ៉ាតិច៥មុខ (មើលរូបទី ៣)។

ថ្មីនេះៗក្រសួងការពារជាតិសហរដ្ឋអាមេរិកបានធ្វើការសិក្សាទៅលើអតីតៈយុទ្ធជនអាមេរិកាំងដែលត្រលប់មកពីសមរភូមិវិញបានបញ្ជាក់ថា ជំងឺផ្លូវចិត្តនិងជំងឺផ្លូវកាយមានទំនាក់ទំនងគ្នាយ៉ាងជិតស្និត។ មានន័យថា ភាគច្រើននៃអ្នកមានជំងឺ ផ្លូវចិត្តមានជំងឺទឹកនោមផ្អែម។

លទ្ធផលការស្ទង់មតិរបស់សមាគមគាំទ្រសុខភាពខ្មែរបានបង្ហាញទៀតថា អ្នកចូលរួមស្ទង់មតិភាគច្រើន(៨៥%)បានជួបពិនិត្យសុខភាពជាមួយគ្រូពេទ្យគ្រួសាររបស់ខ្លួនយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ ប៉ុន្តែលទ្ធផលសុខភាពរបស់ពួកគាត់ពុំមានការជឿនលឿនឡើយ ៕

មើលរូបទី ២

មានការបកស្រាយមួយចំនួនចំពោះលទ្ធផលសុខភាពអន់ខ្សោយរបស់ខ្មែរអាមេរិកាំង ទោះបី៨៥%មានគ្រូពេទ្យគ្រួសាក៏ដោយ។ ជំនាញការសុខភាពខ្លះយល់ថា លទ្ធផលសុខភាពមិនល្អបែបនេះ គឺបណ្តាលមកពីបញ្ហាភាសា និងការខ្វះមធ្យោបាយធ្វើដំណើរ។ លទ្ធផលស្ទង់មតិខាងលើបានបញ្ជាក់ថា អ្នកចូលរួមចំនួន ៣៥% បានឆ្លើយថា ភាសាជាឧបសគ្គក្នុងការទទួលបានការគាំពារសុខភាពដែលមានគុណភាព ចំណែកឯ ១៤% បានឆ្លើយថា ការខ្វះខាតមធ្យោបាយធ្វើដំណើរ គឺជាឧបស័គ្គ ។ ជំនាញការសុខភាពខ្លះទៀតយល់ថា លទ្ធផលសុខភាពមិនបានល្អបែបនេះអាច

តទៅលេខក្រោយ


# GATEWAY FAMILY DENTAL

www.gatewayfamilydental.com • (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)



**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 13 years, she has been in private practices providing all aspects of General Dentistry. Her state of the art dental practic includes x-ray, digital x-rays, paperless patient chart system, and new dental equipments.




**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

Free Teeth Whitening Kit
(with new patient´s x-ray, exam, cleaning at regular price)

**MOST DENTAL INSURANCES ACCEPTED INCLUDING MASSHEALTH**
**FINANCING AVALIABLE**
**យើងទទួលនូវគ្រប់ អ៊ិន ស្វ៊ិន Masshealth**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**
**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**

# ខ្មែរអ្នកជាតិនិយម

តពីលេខមុន

នៅឆ្នាំ១៩៣៧ ដោយវាយយកបានក្រុងប៉េកាំង (Bejing) និងកង់តុង (Kwangtung) ក្នុងឆ្នាំ១៩៣៨ រួចហើយយកកោះហៃណាន (Hainan) នៅឆ្នាំ១៩៣៨ ។

ដូច្នេះនៅពេលសង្គ្រាមលោកលើកទី២ (គ.ស. ១៩៣៩-១៩៤៥ ដែលអង់គ្លេស,បារាំង, សហភាពសូវៀត, សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តដទៃទៀត ច្បាំងជាមួយអាល្លឺម៉ង់ដ៏ , អ៊ីតាលី និងជប៉ុន ) បានផ្ទុះឡើងនោះ ឥណ្ឌូនេស៊ីទាំងមូលឋិតនៅក្នុងសភាពគាបសង្កត់របស់ជប៉ុន ។ រីឯនៅអឺរ៉ុបវិញ អំណាចណាស៊ីអាល្លឺម៉ង់ដ៏បានបង្ខំឱ្យសេនាប្រមុខប៉េកាំងនៃប្រទេសបារាំងចុះហត្ថលេខាសុំចុះចាញ់ នៅថ្ងៃទី១៦ មិថុនា ១៩៤០ ។ ដោយឃើញថា អំណាចបារាំងនៅឥណ្ឌូចិនកំពុងធ្លាក់ចុះក្នុងភាពទន់ខ្សោយត្រដាប់ត្រដួសនោះ ជប៉ុនក៏ឆ្លៀតឱកាសចាត់វិធានការណ៏បញ្ឈប់ការរត់ពន្ធអាវុធដែលយកមកឱ្យចិនជាតិនិយមនៅតាមកំពង់ផែហៃហ្វុង ត្បិតកំពង់ផែទាំងឡាយនៅប្រទេសចិន បានត្រូវកងទ័ពជប៉ុនឡោមព័ទ្ធអស់ហើយ ។ នៅថ្ងៃទី ២៩ មិថុនា ១៩៤០ ឧត្តមសេនីយ៏ជប៉ុនម្នាក់ឈ្មោះ នីស៊ីហារា បានមកដល់



និពន្ធដោយ ឡឹក សំអឿន ហៅ "ផ្កាយព្រឹក"

ហាណូយ រួចទាមទារឱ្យបារាំងបញ្ឈប់ចរាចរលើផ្លូវរទេះភ្លើងដែលចូលទៅខេត្តចិនយុណ្ណាន (Yunnan) ព្រមទាំងឱ្យបិទព្រំដែនចិន-យួនទាំងស្រុង ។ ការគាបសង្កត់របស់ជប៉ុននេះ បានត្រូវឧត្តមសេនីយ៏កាទ្រូ អគ្គទេសាភិបាលបារាំងប្រចាំឥណ្ឌូចិនយល់ព្រមតាមទាំងអស់ ។ ថ្ងៃទី ២០ កក្កដា ១៩៤០ បារាំងបានតែងតាំងឧត្តមនាវី ដឺគូ (Decou) ជំនួសឧត្តមសេនីយ៏ កាទ្រូ ។ ថ្ងៃទី២០ កញ្ញា ឆ្នាំដដែលនោះ រដ្ឋាភិបាលបារាំងនៃសេនាប្រមុខប៉េកាំង បានបញ្ជាដឺគូឱ្យចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅហៃហ្វុង ដែលអនុញ្ញាតឱ្យជប៉ុនឆ្លងកាត់តុងកឹង និងដាក់ទ័ពចំនួន៦,០០០ នាក់នៅខាងជើងទន្លេក្រហម ហើយជប៉ុនក៏អាចប្រើប្រាស់វាលអាកាសយាន៣ នៅតុងកឹង ។ ឯខាងជប៉ុន ក៏យល់ព្រមគោរពអធិបតេយ្យ និងបូរណភាពទឹកដីរបស់បារាំងនៅឥណ្ឌូចិនដែរ ។

ដំណើរដែលជប៉ុនឆក់យកអំណាចនៅលើឥណ្ឌូចិននេះ បានបញ្ចុះកិត្យានុភាពបារាំងយ៉ាងខ្លាំងនៅចំពោះមុខបណ្ដាជននៃប្រទេសបារាំង៣នៅឥណ្ឌូចិន ។ ឯនៅប្រទេសសៀមឯណោះវិញ សៀមក៏ឆ្លៀតឱកាសក្នុងគ្រាដែលបារាំងកំពុងអន់ថយកិត្យានុភាពនេះដែរ ។ ក្នុងខែកញ្ញា ១៩៤០ ពេលដែលបារាំងកំពុងមានវិវាទជាមួយជប៉ុនក្នុងរឿងតុងកឹងនោះ សេនាប្រមុខ ភិបុលសង្គ្រាម រដ្ឋមន្ត្រីទី១ សៀម បានទាមទារយកពីរដ្ឋាភិបាលបារាំងវិញ នូវដែនដីដែលសៀមបានឱ្យទៅឥណ្ឌូចិនបារាំង តាមសន្ធិសញ្ញា១៩០៧ និងទឹកដីមួយភាគទៀតដែលបារាំងបានសន្យាជាមួយសៀមតាមសន្ធិសញ្ញា១៩០៤ និងឆ្នាំ១៩០៧ ថានឹងឱ្យទៅសៀមវិញ នៅពេលណាបារាំងឈប់ត្រួតត្រាឥណ្ឌូចិន ។ ការមិនយល់ព្រមរបស់បារាំងបានជំរុញសៀមឱ្យប្រើកម្លាំងទ័ព ។ នៅចុងខែកញ្ញា ១៩៤០ ភិបុលសង្គ្រាម បានបញ្ជាកងទ័ពសៀមឱ្យធ្វើទុក្ខបុកម្នេញនៅតាមទល់ដែន លាវ-សៀម និងទល់ដែនខ្មែរ-សៀម ។ បារាំងក៏បានតបតទៅសៀមវិញ ដោយទម្លាក់គ្រាប់បែកនាពេលយប់ ទៅលើទីប្រជុំជនសៀមនៅភាគឦសាន ។ ថ្ងៃទី៥ មករា ១៩៤១ កងយោធាសៀមបានចាប់ផ្ដើមកាន់កាប់ភូមិខ្មែរជាច្រើននៅតាមព្រំដែន ។ ដោយសារបរាជ័យនៅលើដីគោក ដឺគូ ក៏បានបញ្ជាធ្វើប្រតិបត្តិការសឹកមួយតាមជើងទឹក ។ ថ្ងៃទី៧ មករា ១៩៤១ ពេលព្រលឹមស្រាងៗ កងនាវាចរបារាំងបានបាញ់បំផ្លាញនាវាស្រុករក្សាឆ្នេរសមុទ្រសៀមឈ្មោះ "ធនបុរី" និងនាវាដ៏ទៃទៀតជាច្រើន ប្រហែល៤៥% នៃកងនាវាសៀមត្រូវខូចខាតប្រើលែងកើត ។

ដោយឃើញព្រឹត្តិការណ៏ទាំងនោះកើតឡើងដូច្នេះ ជប៉ុនក៏បានបង្ខំសៀម និងបារាំងឱ្យធ្វើការសម្រុះសម្រួលគ្នា ក្រោមអធិបតីភាពនៃឧត្តមសេនីយ៏ជប៉ុន ស៊ូ មិក នៅថ្ងៃទី ៣១ មករា ១៩៤១ នៅឯព្រៃនគរ រួចបានចុះហត្ថលេខាយល់ព្រមឈប់បាញ់គ្នានៅលើនាវាល្បាតជប៉ុនមួយគ្រឿងឈ្មោះ "ណាគូរី" ។ ថ្ងៃទី១៧ កុម្ភៈ ១៩៤១ កិច្ចចរចារដើម្បីសន្តិភាពក៏បានចាប់ផ្ដើមឡើងនៅក្រុងតូក្យូ ក្រោមអធិបតីភាពនៃអ្នកតំណាងរដ្ឋាភិបាលជប៉ុនម្នាក់ឈ្មោះ "ម៉ាក់ស៊ូកា" ។ នៅថ្ងៃទី៩ ឧសភា ១៩៤១ កិច្ចសន្យាសន្តិភាពរវាងបារាំង-សៀម ក៏ត្រូវបានចុះហត្ថលេខា ដែលក្នុងនោះចែងថា ប្រទេសបារាំងត្រូវប្រគល់ទៅឱ្យប្រទេសសៀមនូវខេត្តបាត់ដំបង ស្រីសោភ័ណជី

តទៅលេខក្រោយ


NEW ENGLAND INSTITUTE OF HVAC, INC.
ម៉ាស៊ីនកំដៅ, ម៉ាស៊ីនត្រជាក់ និងទូរទឹកកក
ថ្នាក់រៀនពេលថ្ងៃ និងពេលល្ងាច និងផ្ដើមឆាប់ៗនេះ



បំពេញការសិក្សានៅ HVAC គឺសិក្សាតែរយះពេល ១៣សប្ដាហ៏

• សិក្សាដោយពិសោធន៏ផ្ទាល់ដៃ
• ជួយរកការងារធ្វើ
• ផ្ដល់សម្ភារៈឱ្យ
• ថ្នាក់រៀនសិស្សតិច

• GI Bill Education Benefits Approved
• Section 30 Approved

NATE Certifications, EPA Testing, CEU's, OSHA, and Financing Available to those who qualify

គឺជាប្រភពសម្រាប់ឋាមពលបែតង

Call for details: 978.735.4979

NEW ENGLAND INSTITUTE OF HVAC, INC

240 Smith St., Lowell, MA 01851
www.newenglandhvac.com



MARCOTTE LAW FIRM
ក្រុមហ៊ុនមេធាវី Marcotte
45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

• សេចក្ដីគ្រោះថ្នាក់ដល់រូបរាងកាយ
• ពិការភាពដោយសន្តិសុខសង្គម
• គ្រោះថ្នាក់ចរាចរណ៏
• បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
• គ្រោះថ្នាក់នៅការដ្ឋាន
• ច្បាប់គ្រួសារ និងលែងប្ដីប្រពន្ធ
• បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៏

• Personal Injury
• Family Law & Divorce
• Disability
• Traffic Accidents
• Sex & Drug Crimes, OUI
• Work Accidents

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ
(978) 458-1229
www.marcottelawfirm.com

# អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ ភាគទី១១

## ការទាក់ទង និងការ យល់ស្របរវាងអ្នកមាន និងអ្នកក្រ



កឹម សុស មន្ត្រីចូលនិវត្ត ក្រសួងការបរទេស សហរដ្ឋអាមេរិក

**កឹម សុស**

**បញ្ហានៃការទាក់ទង**

អញត្រូវការអី និងទាក់ទងវា? វាស៊ីបាយវា អញស៊ីបាយអញ ។ ខ្ញុំមិនទាក់ទងឱ្យប្រឡាក់ខ្លួនខ្ញុំនឹងពួកអាថោកទាបនោះទេ ។ ខ្ញុំគ្មានការទាក់ទងនឹងពួកចោរពួកពុករលួយនោះទេ។ គេមិនទាក់ទងនឹងយើងទេ ព្រោះយើងក្រ ។ គាត់មិនទាក់ទងនឹងយើងទេ ព្រោះយើងគ្មានផលប្រយោជន៍អីជូនគាត់។ យើងគ្មានការទាក់ទងនឹងគ្នាទេ ព្រោះយើងនៅក្នុងគណបក្សនយោបាយខុសគ្នា។ គេមើលងាយថា យើងក្របានជាគេមិនទាក់ទងនឹងយើង។ កុំតែខ្ញុំទាល់ពេកនោះទេ កុំអីខ្ញុំមិនទាក់ទងគាត់ទេ។ ព្រោះតែវាទាល់ច្រកនោះហើយបានជាវាមកទាក់ទង។

នោះជាឧទាហរណ៍ខ្លះដែលខ្ញុំបានឮនៅស្រុកខ្មែរ។ នេះបង្ហាញឱ្យឃើញថា ក្នុងសង្គមខ្មែរខ្វះការទាក់ទង។

ការទាក់ទង និងការយល់ស្របយើងទាំងអស់គ្នាដឹងថា កាលណាគ្មានការទាក់ទងតែងតែគ្មានការយល់គ្នាទៅវិញទៅមក។ កាលណាមិនយល់គ្នាទៅវិញទៅមកតែងតែមិនយល់ស្របគ្នា។

**ផលវិបាកមកពីការមិនយល់ស្រប**

បែកបាក់គ្នា ពីព្រោះមិនយល់ស្របគ្នា។ សម្លាប់គ្នាមកពីស្អប់គ្នា។ ស្អប់គ្នាមកពីមិនយល់ស្របគ្នា។ ខ្មែរស្លាប់ និងសម្លាប់គ្នាជិតពីរលាននាក់មកពីសង្គ្រាម។ សង្គ្រាមមកពីមិនយល់ស្របគ្នា។ ខាងផ្នែកនយោបាយខ្មែរមានគណបក្សច្រើនមកពីមិនយល់ស្របគ្នា។ កម្មករធ្វើបាតុកម្មប្រឆាំងនឹងរោងចក្រមកពីមិនយល់ស្របគ្នា។

**ធម្មជាតិ និងមនុស្ស**

តាមពិតរឿងមិនយល់ស្របគ្នាជារឿងធម្មជាតិ។ យើងសង្កេតមើលដើមឈើ និងសត្វដែលជាធម្មជាតិ។ អាណាធំជាង អាណាខ្លាំងជាង អាណាច្រើនជាង អាហ្នឹងឈ្នះ អាហ្នឹងដើរធ្វើបាបជិះជាន់អ្នកឯទៀតដែលតូចជាង ខ្សោយជាង តិចជាង។ ចុះមនុស្សវិញជាអ្វី? មនុស្សក៏ជាធម្មជាតិដែរ។ មនុស្សពីដើមក៏មិនខុសពីសត្វប៉ុន្មានដែរ បើសង្កេតអំពីរបៀបរស់នៅ។ មនុស្ស និងសត្វ គឺអ្វីដែលមានជីវិតមានដើមកំណើតជាមួយគ្នា នេះបើតាមលោក ឆលស៍ រ៉បឿត ដរវិណ



(CHARLES ROBERT DARWIN) អ្នកប្រាជ្ញវិទ្យាសាស្ត្រខាងធម្មជាតិជនជាតិអង់គ្លេសនៅសតវត្សរ៍ទី១៩។

**ពេលខ្លះមនុស្សដូចធម្មជាតិ**

ដូច្នេះ ទោះជាមនុស្សចេះហួសពីសត្វ និងធម្មជាតិឯទៀតក្នុងក្រការជាច្រើនរហូតទៅដល់ចេះបង្កើតបច្ចេកវិជ្ជាផលិតឧបករណ៍សម្រាប់ប្រើប្រាសឈ្នះធម្មជាតិច្រើនកន្លែង ដូចជាយន្តអវកាសហោះទៅដល់ព្រះច័ន្ទប្រព័ន្ធទាក់ទងពីទ្វីបមួយទៅទ្វីបមួយទៀតក៏ដោយ ក៏នៅតែមានប្រតិកម្មដោយស្វ័យប្រវត្តិដូចធម្មជាតិដែរបើនៅពេលណាមិនបានគិតជាមុន។ ដូចជាមួយដៃទៅមួយដៃមកគេសម្លាប់យើង យើងសម្លាប់គេវិញជាដើម។

**នៅកន្លែងច្រើនធម្មជាតិឈ្នះមនុស្សតែ មនុស្សនៅមានប្រៀប**

ពិតមែនតែនៅកន្លែងច្រើនទៀត ដូចជាធាតុអាកាសនៅក្រៅ ក្តៅត្រជាក់ ខ្យល់ព្យុះ ជីវំជួយ ភ្នំភ្លើងផ្ទុះជាដើម ដែលមនុស្សមិនទាន់ឈ្នះធម្មជាតិក៏ដោយ ក៏មនុស្សចេះទាក់ទងនិយាយរកផ្លូវស្របគ្នាបាន។

**មធ្យោបាយដើម្បីបង្កើតការទាក់ទង**

ដូច្នេះដើម្បីឱ្យទៅដល់យល់ស្របគ្នាត្រូវមានការទាក់ទងគ្នា។ សំនួរសួរថា តើត្រូវធ្វើយ៉ាងម៉េចដើម្បីឱ្យមានការទាក់ទងគ្នា?

**ឆ្លើយ ជាឧទាហរណ៍ៈ**

ផ្លូវមួយ យើងត្រូវយកអនាគតរបស់ខ្លួនយើងហើយនឹងអនាគតរបស់ប្រទេសជារឿងសំខាន់បំផុត។ យើងត្រូវគិត គឺយើងមិនត្រូវនៅជាធម្មជាតិទៀតទេ។ ដូច្នេះយើងគិតថា ត្រូវតែទាក់ទងគ្នាជាដាច់ខាត គឺថាបើយើងគ្មានការទាក់ទងគ្នាទេ ខ្លួនយើងនិងស្រុកយើងអាចនឹងធ្លាក់ក្នុងមហន្តរាយទៀត។ យើងត្រូវរំលឹកខ្លួនយើងថា តើយើងចង់ឱ្យមានការកាប់សម្លាប់ព្រាត់ប្រាសបងប្អូនម៉ែឪទៀតឬ? បើយើងមិនចាប់ដៃគ្នា ទាក់ទងគ្នាទេ យើងនឹងអាចពើបប្រទះនឹងព្រឹត្តិការណ៍កាប់ **តទៅទំព័រទី ១៣**

# បាតុកម្មប្រឆាំងលោក កឹម សុខា អនុប្រធានគណៈបក្សសង្គ្រោះជាតិបរាជ័យយ៉ាងអាម៉ាស់ដល់ ហ៊ុន សែន

**ប៉ារីស :** លោក ហ៊ុន សែន បានប្រកាសយ៉ាងហ្មឹងម៉ាត់កាលពីថ្ងៃទី៣០ ឧសភានេះ នៅក្នុងវត្តមួយនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមថា "បាតុកម្មនឹងកើតឡើងមិនត្រឹមតែនៅរាជធានីភ្នំពេញប៉ុណ្ណោះទេ គឺមានទូទាំងប្រទេស។ បាតុកម្មនឹងកើតឡើង គ្រប់ទីកន្លែងដែលគាត់( កឹម សុខា ) ទៅ" ។

ឃើញថា ការស្រែកអះអាងនេះ នឹងលទ្ធផលវាផ្ទុយគ្នាស្រឡះ។ បាតុកម្មកាលពីថ្ងៃទី៩ មិថុនានេះ តាមអ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាននៅគ្រប់ទីកន្លែង បើបូកសរុបពេញមួយប្រទេសឃើញថា មិនដល់២០០០០នាក់ទេ។ ឃើញថាចំនួននេះតិចតួចណាស់ បើប្រសិនណាជាយើងប្រៀបទៅនឹងសមាជិកសកម្មដែលគណៈបក្សប្រជាជនកម្ពុជាអះអាង ដូចជាក្រុមទីប្រឹក្សាឃុំមានងារជាង៨០០០នាក់ បូកក្រុមទីប្រឹក្សាស្រុកខេត្ត និងមេភូមិ ព្រមទាំងក្រុមទីប្រឹក្សាឃុំអត់ងារ ។ នេះយើងមិនគិតពីសមាជិកសកម្មជារាជការស៊ីវិល ទាហ៊ាន តំរួត។ ប៉ុន្តែបែរជាគេទៅកែនកូនសិស្ស ព្រះសង្ឃ មនុស្សចាស់មកវិញ ព្រមទាំងសន្យាជូនលុយមួយនាក់ពី២ទៅ៤ម៉ឺនរៀល ។ អ្នកដែលមកខ្លះ ឃើញថា មកដោយបង្ខំចិត្តទាំងលាក់មុខលាក់មាត់ដោយទទូរកន្សែង ។ ក្រោយពីបាតុកម្មនេះមានបាតុករខ្លះមិនសប្បាយចិត្តដោយមិនបានទទួលលុយដូចសន្យា ។ ថែមទាំងមិនឃើញមានពួកអាណិកយួនចូលមករួមទេ ដែលពួកអស់នេះ ជាអ្នកគាំទ្រជើងមុខ។

តាមបាតុករខ្លះបានឱ្យដំណឹងថា ក្នុងមជ្ឈដ្ឋាននិស្សិត ព្រះសង្ឃគេកំញើញ បើមិនចូលរួមទេ គេនឹងដេញចេញពីសាលាពីវត្ត ហើយកូនសិស្សខ្លះគេឱ្យពិន្ទុសូន្យនៅពេលប្រឡង។ ល។

ដោយឃើញមិនមានប្រជាពលរដ្ឋចូលរួមច្រើន ហើយខ្លាចនៅពេលក្រោយបានបាតុករតិចជាងមុនលោក ហ៊ុន សែន ធ្វើជាស្នើឱ្យលោក ជុំ ម៉ី និងជនរងគ្រោះក្នុងរបបខ្មែរក្រហមផ្អាកធ្វើបាតុកម្មប្រឆាំងលោក កឹម សុខា និងរកវិធីតវ៉ាផ្សេងដើម្បីឱ្យការឃោសនា និងការបោះឆ្នោតខែកក្កដាខាងមុខមានបរិយាកាសល្អ: (សូមលោកកុំភណ្ឌច្រឡំបើសិនមានមេដឹកនាំគណបក្សប្រជាជនពិសេស ហ៊ុន សែន ចេញមុខ ឬ ហេង សំរិន ចេញមុខ ឬអ្នកដឹកនាំដទៃទៀតជាសមាជិកអចិន្ត្រៃយ៍ចេញមុខពិតប្រាកដកម្រិតអស់លោកគាំទ្រអត់បានទេ។ បើអស់លោកមិនរត់ចូលដេកក្នុងស្ថានទូតបរទេសទេខ្ញុំថ្វាយបង្គំ) ។

ការនិយាយនេះគឺផ្ទុយនឹងគំនិតពីមុន។ តាមយើងស្គាល់ ហ៊ុន សែន បើប្រសិនណាជាបាតុកម្មនេះមានអ្នកចូលរួមច្រើន ហ៊ុន សែន នឹងពន្យុះឱ្យធ្វើបន្តថែមទៀត។ ការដែល ហ៊ុន សែន សន្យារបៀបនេះមានច្រើនដងមកហើយដូចជារឿងកាប់ព្រៃឈើបើហាមមិនបានសុខចិត្តកាត់កប៉ុន្តែព្រៃឈើនៅតែកាប់ក ហ៊ុន សែន នៅតែ ដដែល ។

ព្រមជាមួយនោះ ហ៊ុន សែន បានបដិសេធន៍ការចោទប្រកាន់ដែលថាគណបក្សប្រជាជនកម្ពុជាជាអ្នកគាំទ្រលោក ជុំ ម៉ី ដឹកនាំធ្វើបាតុកម្មប្រឆាំងលោក កឹម សុខា ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ។ លោកព្រមានថា បើសិនជាគណបក្សប្រជាជនកម្ពុជានៅពីក្រោយបាតុកម្មនោះនោះលោក កឹម សុខា មិនបានសុខទេ គឺប្រាកដជាត្រូវស្វែងរកស្ថានទូតណាមួយដើម្បីជ្រកកោនមិនខាន។ ប៉ុន្តែតាមអ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាននៅគ្រប់ទីកន្លែងថា ក្រុមលោក ជុំ ម៉ី គ្មានមធ្យោបាយរៀបចំបាតុកម្មនេះទាំងលុយទាំងមនុស្ស បើប្រសិនណាជាគណបក្សប្រជាជនកម្ពុជាមិនចេញធ្វើនោះ។ ដូចជាដឹកជញ្ជូនបាយទឹកអនាម័យជាដើម ។ល។ នេះយើងមិននិយាយពីការការពារសន្តិសុខនោះទេ។

ហើយ ហ៊ុន សែន បានព្រមានគណបក្សប្រឆាំងមិនត្រូវទម្លាក់កំហុសឱ្យរដ្ឋាភិបាលជាអ្នកនៅពីក្រោយបាតុកម្មរបស់លោក ជុំ ម៉ី នោះទេ ។ លោក ហ៊ុន សែន បានព្រមានប្តឹងលោក កឹម សុខា ទៅកាន់តុលាការក្រោយការបោះឆ្នោត។ ការដែល ហ៊ុន សែន ព្រមាននេះ គឺគ្រាន់តែយកល្អមើលតែប៉ុណ្ណោះមិនដឹងជារកមូលហេតុប្តឹងយ៉ាងដូចម្តេចទេ គ្រាន់តែគណបក្សប្រឆាំងថា សង្កេតឃើញរដ្ឋាភិបាលជាអ្នកនៅពីក្រោយបាតុកម្មរបស់លោក ជុំ ម៉ី ។

ឯចំណែកលោក ជុំ ម៉ី ក៏រកប្តឹងលោក កឹម សុខា ដែរ ប៉ុន្តែមិនដឹងជារកមូលហេតុអ្វីទេទី ១ លោក កឹម សុខា ប្រកែកថា មិនបាននិយាយទី២ ច្បាប់នេះមិនទាន់ចូលជាធរមានបើយើងមិនលើកចំណោទសួរពីច្បាប់នេះ តើស្របទៅតាមរដ្ឋធម្មនុញ្ញ ឬអត់។

ក្រោយពីបាតុកម្មនេះមកយើងអាចវិភាគនយោបាយថា ប្រជាពលរដ្ឋឈប់គាំទ្រគណបក្សប្រជាជនកម្ពុជាទៀតហើយ ជាពិសេសពីសំណាក់ពួករាជការស៊ីវិលទាហ៊ានតំរួតដែលធ្លាប់បានលាភផលពីអំណាច ។ នេះយើងមិននិយាយពីប្រជាពលរដ្ឋជាទូទៅដែលគ្មានរងគ្រោះដោយសារអ្នកកាន់អំណាចគណបក្សប្រជាជនកម្ពុជានោះទេ។

នេះជាសញ្ញាដែលយើងសង្ឃឹមពីលទ្ធផលបោះឆ្នោតនាថ្ងៃទី ២៨ កក្កដាខាងមុខនេះ។

**លិម តិមយ៉ា បេក្ខជនតំណាងរាស្ត្រគណៈបក្សសង្គ្រោះជាតិ**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ អង្គារ៍ ទី១៨ ខែមិថុនា ឆ្នាំ២០១៣

# គណបក្សប្រឆាំងធ្វើញត្តិអំពាវនាវឱ្យរដ្ឋសភាប្រគល់តំណែងដល់តំណាងរាស្ត្រទាំង២៧រូបវិញ

**ផន បុប្ផា**
**ខេមបូឌា ដេលី**

គណបក្សសង្គ្រោះជាតិបានសុំឱ្យអ្នកគាំទ្ររបស់ខ្លួនចុះហត្ថលេខាលើញត្តិមួយ ដើម្បីអំពាវនាវឱ្យរដ្ឋសភាដែលដឹកនាំដោយគណបក្សកាន់អំណាចប្រគល់តំណែងឱ្យតំណាងរាស្ត្រទាំង២៧រូប ដែលត្រូវបានដកហូតតំណែងកាលពីដើមខែនេះវិញ បើមិនដូច្នេះទេនឹងប្រឈមនឹងផលលំបាក ។

ទម្រង់បែបបទនៃញត្តិបានផ្ញើទៅអ្នកគាំទ្រ និងសមាជិកគណបក្សប្រឆាំងនៅទូទាំងប្រទេស នោះបានលើកឡើងថា រដ្ឋសភាបានបាត់បងធម្មនុញ្ញភាពតាំងពីស្ថាប័ននេះបានដកតំណែងពីតំណាងរាស្ត្រគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ហើយញត្តិនេះក៏បានគំរាមផងដែរថា នឹងធ្វើការតវ៉ាប្រសិនបើតំណាងរាស្ត្ររបស់ខ្លួនមិនបានទទួលតំណែងវិញទេនោះ ។

ញត្តិនោះបន្តថា "យើងបានទាមទារឱ្យតំណាងរាស្ត្ររបស់យើងបានទទួលតួនាទីវិញ ដើម្បីបំរើជាតិដូចដែលបានចែងក្នុងច្បាប់ ។ ប្រសិនបើអស់លោកមិនចាត់វិធានការតាមសំណើររបស់យើងទេ យើងជាប្រជាពលរដ្ឋខ្មែរនឹងធ្វើការតវ៉ានៅទូទាំងប្រទេស ដើម្បីទាមទារឱ្យមានការទទួលស្គាល់តំណាងរបស់យើង ។ រដ្ឋសភាបច្ចុប្បន្នមិនស្របច្បាប់ទេ" ។

លោកស្រី មូរ សុខហួរ អតីតតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ដែលត្រូវបានដកហូតពីតំណែងជាមួយសហសេវិក២៦រូបទៀតនោះ បានមានប្រសាសន៍ថា លោកស្រីរំពឹងថា នឹងមានអ្នកគាំទ្រជាង ១០.០០០នាក់ផ្តិតមេដៃលើញត្តិនេះ ។

លោក មូរ សុខហួរ បានមានប្រសាសន៍បន្ត ថា "កាលពិសប្តាហ៍មុន យើងបានផ្ញើញត្តិនេះរួច ហើយ "ហើយ" ហើយនឹងប្រមូលវាមកវិញនៅចុងសប្តាហ៍នេះ" ។

កាលពីដើមខែនេះគណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាដែលបង្កើតឡើងដោយតំណាងរាស្ត្រ ១២រូបមកពីគណបក្សកាន់អំណាចរបស់លោក-នាយករដ្ឋមន្ត្រី ហ៊ុន សែន លើកឡើងថា តំណាងរាស្ត្រគណបក្សប្រឆាំងរំលោភច្បាប់បោះឆ្នោតតាមរយៈកាន់តំណែងក្នុងគណបក្សពីរនៅពេលតែមួយ ។

អ្នកជំនាញផ្នែកច្បាប់បានហៅសេចក្តីសម្រេចនេះថា មិនត្រឹមត្រូវតាមច្បាប់ឡើយខណៈដែលអ្នកគាំទ្រគណបក្សប្រឆាំងបានលើកឡើងថា វិធានការនេះ គឺជារឿងនយោបាយ ។ ក្រសួងការបរទេសអាមេរិកបានរិះគន់ដល់ការដកហូតតំណែងនេះ ដោយលើកឡើងថា វាផ្ទុយស្រឡះពីស្មារតីនៃដំណើរការលទ្ធិប្រជាធិបតេយ្យ និងបានស្នើសុំឱ្យគេប្រគល់តំណែងឱ្យតំណាងរាស្ត្រទាំងនោះវិញ ។

លោក ជាម យៀប តំណាងរាស្ត្រគណបក្សកាន់អំណាចបានមានប្រសាសន៍កាលពីម្សិលមិញថា សហរដ្ឋអាមេរិកមិនយល់ពីច្បាប់នៅកម្ពុជាទេ ហើយក៏គ្មានតួនាទីក្នុងការអធិប្បាយអំពីការដកហូតតំណែងនេះដែរ ។ លោកក៏បានមានប្រសាសន៍ផងដែរថា ញត្តិនោះគ្មានប្រយោជន៍ទេ ទោះបីជាប្រមូលបានស្នាមមេដៃរាបលានក៏ដោយ ។

លោកបន្តថា "ប្រសិនបើគេអាចប្រមូល "ស្នាមមេដៃពីអ្នកគាំទ្រ"បានចំនួន១៤.៥លានមេដៃ ដោយមាន"ការគាំទ្រពី"សហរដ្ឋអាមេរិក និងកាសែតខេមបូឌាដេលី...ក៏ពួកគេនៅតែមិនត្រូវច្បាប់ដែរ... ៕

ប្រែសម្រួលដោយ ហម សុផាណា

# Opposition Petitions to Regain Assembly Seats

BY PHORN BOPHA
THE CAMBODIA DAILY

The opposition has asked its supporters to sign a petition that on the CPP-led National Assembly to reinstate 27 of its law- makers who were stripped of their positions earlier this month, or face consequences.

The petition forms, which have been sent to opposition supporters and party members across country, state that the Nation- al Assembly lost legitimacy when it stripped the SRP and Human Rights Party lawmakers of their jobs, and threatens protests if they are not reinstated.

"We demand that our lawmakers are allowed to be on their duty to serve the Cambodian nation as stipulated by the law. In case you do not take action in compliance with our suggestion, we, Cambodian citizens, will hold protestsacross the country demanding the recognition of our representatives. The current National Assembly is not legitimate," the petition states.

Mu Sochua, SRP lawmaker and electoral candidate for the Cambodia National Rescue Party (CNRP), who was stripped of her National Assembly position along with 26 colleagues, said that she expected more than 10,000 supporters to thumbprint petition papers.

"We have sent the letters out last week [and] we will collect them late this week," Ms. Sochua said.

Earlier this month, the National Assembly's permanent committee, which is made up of 12 lawmakers solely from Prime Minister Hun Sen'sruling CPP, said that: the opposition lawmakers were violating the election law by holding member-ship of two partiesat the same time.

Legal experts called the decisions legally questionable, while opposition supporters said the movewas politically motivated The U.S.State Department criticized the ex-women,pulsion, saying it was in stark contradiction to the spirit of a healthydemocratic process, and asked forthe lawmakers to be reestablished.

CPP lawmaker Cheam Yeapyesterday said that the U.S. hadno knowledge of Cambodianlaws, and was therefore in no position to comment on the expulsion. He also said that the petition wasuseless, even if millions of signaturewere garnered "If they mantel 'Sage to collect 14.5 million [signatures] with [support of] the USAand the Cambodia Daily ... they can still not flout the law," he Said.

# សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមពន្យារពេលបើកមហាសន្និបាតបណ្តេញលោក ជុំ ម៉ី

**គុច ណារ៉ែន**
**ខេមបូឌា ដេលី**

សមាគមក្នុងស្រុកមួយរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបានសម្រេចរង់ចាំរហូតដល់ក្រោយការបោះឆ្នោតជាតិនៅថ្ងៃទី២៨ ខែកក្កដាខាងមុខនេះ ទើបបើកកិច្ចប្រជុំមួយស្តីពីការបណ្តេញលោក ជុំម៉ី ប្រធានសមាគមរបស់ខ្លួនដោយសារលោកមានការគាំទ្រនយោបាយខ្លាំងពេកចំពោះរដ្ឋាភិបាល ។

ថ្នាក់ដឹកនាំជាន់ខ្ពស់របស់សមាគមជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យលើកលែងតែលោក ជុំម៉ី ប្រកាសផែនការរបស់ខ្លួនកាលពីថ្ងៃទី៨ ខែ មិថុនា ក្នុងការបើកមហាសន្និបាតលើកទី១ ដែលមិនធ្លាប់មានក្នុងគោលបំណងដកមេដឹកនាំរបស់ខ្លួន ប៉ុន្តែមិនបានផ្តល់កាលបរិច្ឆេទសម្រាប់ព្រឹត្តិការណ៍នេះទេ ។

នៅក្នុងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមេដឹកនាំជាន់ខ្ពស់ទាំងនេះបានចោទប្រកាន់លោក ជុំម៉ី ថាបានធ្វើឱ្យប៉ះពាល់ដល់ឯករាជភាពរបស់សមាគមនេះ តាមរយៈការយកសមាគមនេះធ្វើយុទ្ធនាការនយោបាយជាសាធារណៈ ដើម្បីទាមទារឱ្យលោក កឹម សុខា សូមអភ័យទោសចំពោះពាក្យសម្តីដែលលោកបាននិយាយថា ប្រទេសវៀតណាមបានប្រឌិតការធ្វើទារុណកម្មលើប្រជាពលរដ្ឋរាប់ពាន់នាក់នៅគុកទួលស្លែងអំឡុងរបបខ្មែរក្រហម ។ លោក កឹម សុខា បានបដិសេធថា មិនបាននិយាយបែបនេះទេ ។

កាលពីថ្ងៃទី៩ ខែមិថុនា លោក ជុំ ម៉ី ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូចដែលបានរួចជីវិតពីគុកទួលស្លែងនោះបានដឹកនាំប្រជាពលរដ្ឋរាប់ពាន់នាក់ធ្វើបាតុកម្មប្រឆាំងលោក កឹម សុខា នៅរាជធានីភ្នំពេញដែលអាជ្ញាធរមូលដ្ឋានបានផ្គត់ផ្គង់សព្វបែបយ៉ាងចាប់តាំងពីទឹករហូតដល់ការធ្វើដំណើររបស់អ្នកចូលរួម និងសម្ភារៈធ្វើការតវ៉ា ។ អំឡុងពេលធ្វើការតវ៉ានេះលោក ជុំម៉ី បានរិះគន់គណបក្សលោក កឹម សុខា គឺគណបក្សសង្គ្រោះជាតិ និងបានកោត

**តទៅទំព័រទី ១៨**

# បក្សនយោបាយដេញដោលគ្នាពីបញ្ហាធំៗដោយគ្មានការចូលរួមពីខាងគណបក្សប្រជាជន

kColin Meyen និង ផន បុប្ផា
**ខេមបូឌា ដេលី**

កាលពីថ្ងៃអាទិត្យស្ថានីយ៍វិទ្យុជាតិបានដកកម្មវិធីដែលសមាជិកសភាមួយក្រុមបានមកជួបជុំគ្នា ដើម្បីពិភាក្សាពីបញ្ហារបស់ស្ត្រីព្រោះគ្មានបេក្ខជនមកពីគណបក្សប្រជាជនកម្ពុជាម្នាក់ណាបានមកចូលរួមក្នុងកិច្ចពិភាក្សានេះឡើយ ។ គណបក្សកាន់អំណាចបានបដិសេធចំពោះការអញ្ជើញឱ្យចូលរួមវេទិកានយោបាយចំនួនពីរដែលរៀបចំក្នុងរាជធានីភ្នំពេញកាលពីពីរសប្តាហ៍មុន និងពិធីសន្យាប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ អង្គការក្រៅរដ្ឋាភិបាលក៏បានលើកឡើងដែរថា តំណាងមកពីគណបក្សប្រជាជនកម្ពុជាក៏មិនបានមកចូលរួមក្នុងកិច្ចពិភាក្សាដេញដោលតូចៗមួយចំនួនដែលរៀបចំឡើងនៅទូទាំងប្រទេសផងដែរ ។

ទោះបីមានកិច្ចខិតខំប្រឹងប្រែងពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើតវេទិកាសម្រាប់គណបក្សនយោបាយសំខាន់ៗក្នុងប្រទេសកម្ពុជាពិភាក្សាអំពីគោលនយោបាយរបស់ខ្លួនមុនការបោះឆ្នោតជាតិ នាថ្ងៃទី២៨ ខែកក្កដា ក៏ដោយក៏គណបក្សប្រជាជនកម្ពុជាដែលសព្វថ្ងៃមានអាសនៈចំនួន៩០ ក្នុងចំណោមអាសនៈសរុបចំនួន១២៣នៅក្នុងរដ្ឋសភានៅតែបដិសេធមិនចូលរួមដែរ ។

សម្រាប់អ្នកខ្លះនិយាយថា ការបដិសេធរបស់គណបក្សកាន់អំណាចមិនព្រមចូលរួមនៅក្នុងកិច្ចពិភាក្សាដេញដោលជាសាធារណៈនេះ គឺហាក់ដូចជាគោលនយោបាយមួយអ៊ីចឹង ។

លោក វ៉ន ពៅ ប្រធានសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធដែលរៀបចំវេទិការមួយក្នុងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃព្រហស្បតិ៍ដោយមានសមាជិកមកពីគណបក្សនយោបាយសំខាន់ៗត្រូវបានអញ្ជើញឱ្យមកចូលរួមពិភាក្សាអំពីបញ្ហាដីធ្លីសិទ្ធិមនុស្ស និងអំពើពុករលួយបាន **តទៅទំព័រទី ៧**

# Red Rose RESTAURANT

ភោជនីយដ្ឋាន
កុលាបក្រហម

ម្ចាស់ថ្មី _ម្ហូបឈ្ងុយឆ្ងាញ់

អញ្ជើញមកចូលរួមមិនខុសបំណងទេ សូមអរគុណ!

**Mon-Sun**
**8am -8pm**





សម្លម្ជូរ គ្រឿង $11.99







* ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
* សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

**(978) 452-5400**

**Pailin Plaza**
**716 Middlesex St. Ste 1**
**Lowell, MA 01851**

# GLOBAL REALTY NETWORK LLC

*Integrity, Exceptional Service, Outstanding Results*



5 Juniper Street, Lowell, MA 01852
Asking Price: $399,900

New construction Colonial home with 4 bedrooms, 2.5 baths , a fire place, 2 car garage, large kitchen with breakfast nook, and a laundry room on the first floor with the half bath.

Business for Sale
1344 Gorham Street Lowell, MA 01852 Asking Price: $89,900

The best of both world: a convenient store and a laundromat together in one location. The convenient store also provides Western Union Money Transfer services, bill payments, and money order. The store also accepts WIC and EBT. The laundromat also provides wash and fold services at $0.75 per pound, and dry cleaning services. You can stop by and check out the business.





Paul-Rathal Yem, CBR/CDPE/AREAA
HUD Approved Broker
licensed in MA,RI & CT
Global Realty Network, LLC
16 Pine Street, Suite 13, Lowell, MA 01851
(800) 494-2400 Toll Free (888) 789-0954 Fax - (617) 459-3000 Cell
www.GlobalRealtyNetwork.com

## កម្មវិធីថែសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

. នាងថែខ្ញុំដូចជាម្តាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
. នាងស្រឡាញ់និងថែខ្ញុំដូចជីដូនបង្កើត
. នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្តាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
. ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
. នាងរលឹកពេលដែលខ្ញុំត្រូវញាំថ្នាំ គ្រប់ពេលវេលា
. នាងជូនខ្ញុំដើរលេងលំហែកាយ
. នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
. កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
. ព្រឹទ្ធាចារ្យជាដុំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថែទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ
សម្រាប់ពត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

# HOME CARE Aurora



LOWELL ELDER CARE
978-596-1111

# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

## អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ្ឋានក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

## ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។



## មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

## Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

សូមហៅលេខទូរស័ព្ទ (978) 596-1111



# ភោជនីយដ្ឋានស៊ីម ភ្លីខ្មែរ

Simply Khmer Restaurant



Open 7 days a week from 8AM–9PM
បើករៀងរាល់ថ្ងៃ ចាប់ពីម៉ោង៨ព្រឹក ដល់ម៉ោង ៩យប់
26 Lincoln #4, Lowell, MA 01851 • (978) 454-6700
គេហទំព័រ: www.simplykhmerrestaurant.com



# SIM'S Home Improvement

Major Sim Enterprises, Inc.

## ជាងសំណង់តាស៊ីម




Repairing •Remodeling •Additions
ជួសជុល កែលំអរ សង់បន្ថែម

- Kitchen ចង្ក្រានបាយ
- Livingroom បន្ទប់ទទួលភ្ញៀវ
- Bathroom បន្ទប់ទឹក
- Bedroom បន្ទប់ដេក
- Roofing ដំបូល
- Siding ជញ្ជាំង
- Window បង្អួច
- Door ទ្វារ
- Basement ជាន់នៅក្រោមដី
- Additions បន្ទប់បន្ថែម

Residential • Commercial • Industrial
ទទួលប្រាក់គ្រប់ប្រភេទ
Bank Loan, Insurance, Compensation, Credit Debit, Check &Cash
More information call: 1.978.452.7467

www.SimsHomeImprovement.com
Boreth@SimsHomeImprovement.com

# ភូឡាបប៉ៃលិន

GRAND OPENING

Asian & International foods Market

## ហាងឧបភោគបរិភោគ ទើបប្ដូរម្ចាស់បើកថ្មី

6 Branch St. Lowell MA 01851 (978)-459-1780

- មានលក់បន្លែបង្កាស្រស់គ្រប់មុខ មានផ្លែឈើមកដល់ថ្មីរាល់ថ្ងៃ
- ត្រីសាច់ គ្រឿងសមុទ្រ ម្ហូបហាលស្ងួត គ្រឿងកំប៉ុង ម្ហូបគ្រប់យ៉ាង មកពីអាស៊ី -អង្ករគ្រប់ធន់
- មានម្ហូបឆ្អិនស្រេច ដាកឡូវ ទាខ្វៃ ចៅខ្វៃ នុំនែក ។ល។
- មានតំរាន់ចុះថ្លៃច្រើនមុខរាល់ថ្ងៃ :

យើងទទួល Credit Card គ្រប់យ៉ាងទទួល Food Stamp Card

មានកន្លែងចតរថយន្តខាងមុខ និងខាងក្រោយហាងធំទូលាយ

DISCOVER VISA MasterCard SNAP




Fresh Produce
- Poultry
- Meats
- Fish and Seafoods
- Veggebles
- Can foods
- Kitchenwares etc

ម៉ោងបើកចាប់ពីម៉ោង៩:00AM-៨:00PM



កំប៉ុងធំ $7.99 | កំប៉ុងតូច $3.99 | អង្ករខ្មែរមាសសរ $15.99



$3.75 /ដប | $3.75 /កញ្ចប់ | $1.99 /កំប៉ុង | $1.99 /កញ្ចប់ | ខ្ទិះដូង $1.25/កំប៉ុង ប្រអប់$24( 24កំប៉ុង ) | $11.99 /ប្រអប់





# ពេទ្យធ្មេញសំរាប់គ្រួសារ

## Caring Dental For ALL Ages




FREE
Teeth Whitening
New patients get a complimentary teeth whitening kit with completed exam, cleaning & x-rays at regular price. Cannot be combined with any other offers. Expires 07/27/13

"EX CLUSIVE OFFER"
$55.00
Limited Time New Patient Special
(Regular Discount $55.99 a $250 Value)
Present coupon for discount. Includes exam, bite-wing x-ray & cleaning. Cannot be combined with other offers or insurance. Expires 07/27/13

COMPLETE ផ្ដល់គ្រប់សេវាកម្ម Services

- Cosmetic Dentistry
- Cosmetic Fillings
- Crowns & Bridges
- Dentures
- Extractions
- Implant Crowns
- Root Canal Therapy

- ត្រួតពិនិត្យទៀតទាត់ពេល
- សំអាតធ្មេញ
- ដងធ្មេញព្រាញធ្មេញ
- ដកសរសៃធ្មេញ
- ស្រោប-តម្រឹម និងប៉ះធ្មេញ
- ធ្វើធ្មេញឱ្យស
- បំពេញធ្មេញប្រហោង
- ដកធ្មេញ

Convenient LOCATION
Next to Bank of America on Chelmsford Street



Most Forms of Insurance & Payment
ACCEPTED ទទួលគ្រប់ អ៊ិនស្វិរិន
MassHealth • Cigna • Aetna
Amex • Discover • Visa • Mastercard

យើងមានអ្នកនិយាយភាសាខ្មែរ អង់គ្លេស ស្ពានីស និងវៀតណាម សូមទូរស័ព្ទ 978-455-4039 ដើម្បីណាត់ជួបនៅថ្ងៃនេះ

724 Chelmsford Street • Lowell, MA • 978-455-4039
www.BrightSmiles–Dental.com



# ONEWORLD PHARMACY

Expect Excellence

## ឱសថស្ថានខ្មែរ

នៅក្រុងឡូវែល ដំបូងបង្អស់



Soriya Sok, R. Ph. (Owner)

First Khmer Pharmacy in Lowell
12 years as a retail drug store pharmacist

សួស្ដី !ឱសថស្ថានខ្មែរនៅឡូវែល
- យើងយកថ្នាំជូនដល់ផ្ទះ
- ឱសថការី និយាយនិងសរសេរខ្មែរ
- ពិគ្រោះពីថ្នាំដែលពេទ្យចេញឲ្យ
- អាចស្នើឲ្យចែកថ្នាំ តាមពេលប្រើ
- អាចស្នើឲ្យកាត់ថ្នាំគ្រាប់ជាភាគតូចៗ
- ទទួលយកអ៊ិនស្វិរិន ស្ទើរគ្រប់ធុន
- ប្ដូរកន្លែងបើកថ្នាំជូនបាន



One World Rx
HealthMart Pharmacy
www.pneworldpharmacy.org

Hours of Operation
Monday-Friday: 9AM-7PM
Saturday: 9AM-4PM
Closed Sunday

138 Highland Ave., Unit 5
Lowell, MA 01851

Health Mart PHARMACY
គ្រូពេទ្យអាចបញ្ជាឲ្យទិញថ្នាំតាមទូរស័ព្ទ ហ្វាក់ និង E-script បាន

Tel: 978-455-4066 Fax: 978-455-1578

## តមកទំព័រទី ១ សិស្សសាលា Moody និង Lincoln...

ហើយចេះប្រើប្រាស់ "លុយ"ក្នុងជីវិតរាល់ថ្ងៃបានប្រសើរដោយខ្លួនឯង ។

ក្នុងតំបន់ក្រីក្រម្តាយឪពុកមានវិជ្ជា និងតម្លា





ភាពស្ទួចស្តើងក្នុងការពន្យល់ និងបង្ហាត់កូនពីសេដ្ឋកិច្ចគ្រួសារពីចំណូល និងចំណាយពីការសន្សំពីតម្លៃនៃ"លុយ"ម៉្លោះ ហើយទម្លាប់នៃឪពុកម្តាយនិងឆ្លងទៅកូនជាបន្តធ្វើឱ្យមានវិបត្តិដល់គ្រួសារជំនាន់ក្រោយបានផង ។ បន្ថែមពីនេះគ្រួសារនៃសហគមន៍ខ្មែរដែលជាពលរដ្ឋថ្មីនៃដែនដីអាមេរិកនេះ ក៏ពុំនាំយកនូវទំនៀមទំលាប់ស្តីពី"លុយ" ឬថវិកាក្នុងគ្រួសារ ឬមេរៀនអ្វីពីសេដ្ឋកិច្ចមកជាមួយជាមរតកប្រចាំត្រកូលសំរាប់រស់នៅទីនេះទេ ម៉្លោះហើយមានសេចក្តីត្រូវការពឹងផ្អែកការអប់រំពីវិស័យនេះដល់កូនចៅទាំងស្រុងដែលជាហេតុធ្វើឱ្យកម្មវិធីអប់រំរបស់ខ្មែរ Washington Saving Bank មានគុណសម្បត្តិថ្លៃថ្លាក្នុងសហគមន៍ខ្មែរ ។ កុមារាកុមារីមកពីអាស៊ីជាច្រើនបានមកទទួលសញ្ញាប័ត្រពីតំណាងធនាគារវ៉ាស៊ីនតុនសេវិញ

ស្ទួន និងវិច្ឆិកា កាលពីថ្ងៃ ទី១៤ និងទី១៨ មិថុនា ២០១៣ជាមួយសិស្សទាំង៦០០រូបយ៉ាងរីករាយ ។



កម្មវិធីសិក្សានោះឈ្មោះ "Super Saving" បង្រៀនដោយ វិច្ឆិកា ខង ដែលយកតាមចំណេះដឹងពីលុយដល់សហគមន៍ ជាពិសេសដល់យុវជន ។ សិស្ស៦២៤នាក់បានចូលរួមកម្មវិធី ហើយមកដល់ខែមិថុនា ឆ្នាំ២០១៣នេះ សិស្សជាងបីរយ នាក់កំរិតថ្នាក់ទី៣ និងទី៤ ដាក់ប្រាក់សន្សំក្នុងធនាគារបាន$28.921.27 ហើយ ៕

**ខ្មែរផុស ស.រ.អា**






## តមកទំព័រទី ៥ អ្នកក្រ និងអ្នកមាននៅប្រទេសខ្មែរ...

សម្លាប់ព្រាត់ប្រាស់បងប្អូនម៉ែឪនោះទៀតមិនខាន។

ផ្លូវមួយទៀត គឺអ្នកមាននិងអ្នកក្រ។ អ្នកមានត្រូវគិតថា អ្នកទាំងអស់ គឺទាំងអ្នកមាន និងទាំងអ្នកក្រជាទីផ្សារដែលបណ្តាលឱ្យខ្លួនទៅជាអ្នកមាន។ ហើយអ្នកក្រត្រូវគិតថាអ្នកមានមានអ្វីខ្លួនត្រូវការជាចាំបាច់ដែលអាចយោងខ្លួនឱ្យផុតពីភាពក្រីក្រហើយឱ្យអាចទៅជាអ្នកមានបាន ។ ត្រង់នេះមានន័យថា អ្នកមានត្រូវការផ្សារ។ បើគ្មានផ្សារទេ អ្នកមាននឹងអាចទៅជាក្រវិញបាន។ ចំពោះអ្នកក្រវិញ បើគ្មានអ្នកមានទេ មុខជាមានការលំបាកយ៉ាងខ្លាំងគឺមកពីការខ្វះខាតអ្វីៗដែលខ្លួនត្រូវការចាំបាច់។ ដូច្នេះមានន័យថា អ្នកទាំងពីរ គឺអ្នកមាន និងអ្នកក្រត្រូវការគ្នាទៅវិញទៅមក។ ហើយដើម្បីនឹងឱ្យមានការត្រូវការគ្នាទៅវិញទៅមកបានទាល់តែការទាក់ទងគ្នា។

**មធ្យោបាយនាំឱ្យការទាក់ទងឋិតថេរជាប់យូរ**

យើងឃើញថា ការទាក់ទងនៅក្នុងឧទាហរណ៍ទាំងពីរខាងលើនេះ គឺជាការទាក់ទងដែលសុទ្ធតែមកពីការបង្ខំចិត្ត។ តាមច្បាប់ធម្មជាតិអ្វីដែលមកពីការបង្ខំមិនឋិតថេរជាប់បានយូរទេ។ ដូច្នេះ ដើម្បីឱ្យការទាក់ទងឋិតថេរជាប់បានយូរត្រូវរកមធ្យោបាយ ដើម្បីជួយធ្វើឱ្យភ្លេចការបង្ខំចិត្តនោះ។ តើធ្វើយ៉ាងម៉េច ដើម្បីរំសាយកំហឹងដែលមកពីការបង្ខំចិត្តនោះបាន ?

សូមយកឧទាហរណ៍មកបង្ហាញ។ នៅឆ្នាំ១៩៤៥ គឺនៅសង្គ្រាមលោកលើកទីពីរ អាមេរិកាំងទំលាក់គ្រាប់បែកបរមាណូលើប្រទេសជប៉ុនបង្ខំចិត្តជប៉ុឱ្យចុះចាញ់ជប៉ុនក៏សុខចិត្តចុះចាញ់។ តាមធម្មតាអ្នកចាញ់ខឹងណាស់ ។ នៅពេលជប៉ុនចុះចាញ់ភ្លាមអាមេរិកាំងចាប់ផ្តើមជួយជប៉ុន ជាពិសេសខាងសេដ្ឋកិច្ច។ តាំងពីនោះមកការទាក់ទងរវាងជប៉ុននិងអាមេរិកាំងឋិតថេរជាប់ល្អរហូតមកដល់ពេលនេះ។ ហើយមិនតែប៉ុណ្ណោះប្រទេសជប៉ុនទៅជាប្រទេសអ្នកមានទៀត។

**ជោគជ័យត្រូវនៅក្នុងដៃអ្នកមាន**

ដូច្នេះ ចំពោះខ្មែរ គឺអ្នកមាន និងអ្នកក្រនៅពេលមានការទាក់ទងហើយនោះ អ្នកមានគួរចាប់ផ្តើមធ្វើជាអ្នកដឹកនាំដោយឧស្សាហ៍អញ្ជើញនាំអ្នកក្រមកអង្គុយទល់មុខគ្នាក្នុងភាពស្និទ្ធស្នាលនឹងគ្នានិយាយគ្នាស្តាប់គ្នាឱ្យយល់គំនិតគ្នា គឺអ្នកមានត្រូវយល់អ្នកក្រ ហើយអ្នកក្រត្រូវយល់អ្នកមានរួចរកផ្លូវជួយគ្នាទៅវិញទៅមក។

លើកក្រោយនឹងរែកញែកអំពីប្រសទ្ធិភាពនៃការស្តាប់៕


វត្តធម្មិការាម នៃ រដ្ឋរ៉ូដអៃឡិន្ត
Wat Thormikaram of Rhode Island,Inc.

# បុណ្យបញ្ចុះខណ្ឌសីមា



ភិក្ខុ ប៉ែន ថុល បញ្ញាបុត្តោ
ប្រធានគណកម្មការ



ខ្ញុំព្រះករុណាអាត្មាភាព និងពុទ្ធបរិស័ទចំណុះជើងវត្តធម្មិការាម ហៅវត្តចាស់ ទីក្រុងប្រូវិដិន បាន
បានមូលមតិគ្នាជាឯកច្ឆ័ន្ទផ្តួចផ្តើមធ្វើបុណ្យបញ្ចុះសីមា ព្រះវិហារដែលទើបនឹងសាងសង់ហើយ
ថ្មី ចំណាយអស់បច្ច័យ៣៣ម៉ឺនដុល្លារ ដើម្បីជាផលប្រយោជន៍ក្នុងព្រះពុទ្ធសាសនាពិធីបុណ្យ
នេះនឹងប្រព្រឹត្តទៅនៅថ្ងៃសុក្រ-សៅរ៍-អាទិត្យ ទី៥-៦-៧កក្កដាឆ្នាំ២០១៣
Friday-Saturday-Sunday July 5-6-7,2013
177-179 Hanover Street, Providence, RI 02907
Tel: (401)272-4641 ឬ (401) 688-6238
វត្តធម្មិការាមនេះមានវ័យចំណាស់ជាង៣០ឆ្នាំហើយ មានកេរ្តិ៍ឈ្មោះល្អក្នុងការទ្រទ្រង់ព្រះពុទ្ធ
សាសនានៅរ៉ូដអៃឡិន្តនេះឱ្យបានរុងរឿង ដោយសារស្នាព្រះហស្តព្រះគ្រូចៅអធិការ
បន្តបន្ទាប់មានព្រះមហាឃោសនន្ទ បន្ទាប់មកមានព្រះតេជគុណ តឹម ផន រួចមកមាន
ព្រះតេជគុណ ម៉ី រស់ បន្ទាប់មកទៀត មានព្រះតេជគុណ ព្រុំ សៀន ....។
អាស្រ័យហេតុនេះអាត្មាភាពយើងខ្ញុំទាំងអស់គ្នា សូមអារតនានិមន្ត និងអញ្ជើញលោក លោកស្រី
អ្នកនាងកញ្ញាបងប្អូនព្រមទាំងញាតិមិត្តជិតឆ្ងាយ មេត្តាអញ្ជើញមកចូលរួមចាប់មគ្គផលជួយ
ឧបត្ថម្ភពិធីបុណ្យឱ្យបានអធិកអធម និងអនុមោទនាទទួលយកផលានិសង្សរៀង១ខ្លួន ៕



# ផ្សារអាតាឡង់ទិក

Atlantic Market
135 main St, Danbury, CT 06810
203-830-3068




ផ្សារនេះមានម្ចាស់ឈ្មោះ **ដាន់ ស៊ីង** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។
**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa
**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០




**ទីផ្លាចតរថយន្តឥតគិតថ្លៃ**



# តមកពីទំព័រទី ៧ ខ្មែរក្រោមក្នុងជំលោះដ៏ធំធេងមួយ

*ពិភពលោកនា១សប្តាហ៍ បន្ទាប់សួរដោយ សាន សុវិតមានអត្ថន័យដូចតទៅ :*


គ្រីស្តុហ័រ ង៉ោ ប្រធានថ្មី

**គ្រីស្តុហ័រ ង៉ោ :** ខ្ញុំជម្រាបថា ចម្លើយព្រះតេជគុណ យេង តូច មិនត្រឹមត្រូវទេ លោកថា "ខ្ញុំមិនដែលមកវត្ត ហើយមកចង់កាន់កាប់វត្ត" តាំងតែពីពុទ្ធបរិស័ទជួបជុំចង់បង្កើតវត្តឆ្នាំ១៩៩៣ គឺខ្ញុំនេះជាអ្នកឈរឈ្មោះទិញវត្ត -ខ្ញុំក៏ជាអ្នកធានាលោកសង្ឃបីអង្គឱ្យមកគង់វត្តសុរិយារង្សី ពីព្រោះបើគ្មានកសាងលោកម៉េចគេហៅវត្តទៅបាន? ខ្ញុំជាកូនខ្មែរមានស្នាដៃបានកសាងវត្តរៀបចំវត្តមានដំណើរការណ៍បានសុខសាន្តជារហូតមកដល់ពេលដែលព្រះសង្ឃពីរអង្គនេះមកគង់នៅវត្តសុរិយារង្សីនេះ...

**សាន សុវិត :** មូលហេតុអ្វីក៏មានកើតហេតុទំនាស់នៅវត្តសុរិយារង្សី?

**គ្រីស្តុហ័រ ង៉ោ :** លោក អៀង ភិរុណ មកពីរដ្ឋហ្វ្លរីដា ឆ្នាំ២០១១ ហើយលោក យេង តូច មកពីហ្វ្លរីដា ដែរ ឆ្នាំ២០១២ ហើយ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១២ លោក ភិរុណ បានលុបឈ្មោះលោក ថាច់ ជិន ជាអតីតប្រធានគណកម្មាការវត្ត ហើយដាក់បញ្ចូល អៀង ភិរុណ ជាហិរញ្ញិកដោយគ្មានការអនុញ្ញាតិពីគណកម្មាការវត្តទេបញ្ហាហ្នឹងចាប់ផ្តើមពីពេលហ្នឹងមកថ្ងៃ២១ តុលា ២០១២ លោក ថាច់ ជិន បានបើកការប្រជុំមួយដោយស្រាយរឿងហ្នឹងតែមិនបានសម្រេច ហើយលោកក៏លាលែងទៅ...

**សាន សុវិត :** ចុះលោកទាំងពីរអង្គនោះចង់បានស្អី?

**គ្រីស្តុហ័រ ង៉ោ :** ខ្ញុំក៏មិនដឹងថា ចង់បានអ្វីដែរ តែពីក្រោយខ្នងមានក្រសួងមួយគោលបំណងគេចង់បានវត្តសុរិយារង្សីហ្នឹងហើយ

**សាន សុវិតៈ** តាមដឹងហ្នុងព្រះតេជគុណ យេង តូច ជាសមាជិកសហព័ន្ធខ្មែរកម្ពុជាក្រោម! បានសេចក្តីថា សហព័ន្ធចង់បានវត្តហ្នឹងគ្រប់គ្រង

**គ្រីស្តុហ័រ ង៉ោ :** បានយកវត្តធ្វើទីស្នាក់ការ !

**សាន សុវិត :** តើលោកពីអង្គហ្នឹង ឬសហព័ន្ធមានសិទ្ធយកវត្តសុរិយារង្សីហ្នឹងទទេៗអីចឹងបានទេ នៅពេលដែលវត្តទិញដោយ លោក គ្រីស្តុហ័រ ង៉ោ រួចមកប្រែជាវត្តសុរិយារង្សី?

**គ្រីស្តុហ័រ ង៉ោ :** លោកពីរអង្គនោះ តាមពិតជាភ្ញៀវទេ !

**សាន សុវិត :** ភ្ញៀវដូចជារឿងនិទានមួយនោះថា "សេះឃើញគោស៊ីស្មៅហាលភ្លៀង នឹកអាណិតក៏អូសឱ្យមកជ្រកក្រោមផ្ទះឃើញស្រួលក៏គោរុលម្តងបន្តិចៗ ក៏យកដីជារបស់ខ្លួន"ដូចនេះឬ?

**គ្រីស្តុហ័រ ង៉ោ :** ដូច្នេះខ្ញុំចង់បញ្ជាក់ជូនលោកអ្នកស្តាប់វិទ្យុពិភពលោកឱ្យដឹងថា អ្នកណាដែលធ្វើត្រូវ ធ្វើខុស

**សាន សុវិត :** លោក គ្រីស្តុហ័រ ង៉ោ មានស្គាល់លោក សឹង សុងសឹង នោះដែរ ឬទេ?

**គ្រីស្តុហ័រ ង៉ោ :** ខ្ញុំមិនដែលដឹងថា រូបរាងអ្នកហ្នឹងយ៉ាងម៉េចទេ ពេលចប់សង្គ្រាមហើយខ្ញុំក៏ត្រូវជាប់គុក៦ឆ្នាំ ចេញមកវិញក៏ភៀសមកប្រទេសខ្មែររួចមកស.រ.អាឆ្នាំ១៩៨៣ រឿងនយោបាយខ្ញុំឥតដឹងទេ ។

**សាន សុវិត :** អ៊ីចឹងតាមលោករឿងហ្នឹងបង្កើតដោយភ្ញៀវទាំងពីរអង្គហ្នុង

**គ្រីស្តុហ័រ ង៉ោ :** ពីរឿងចូលឆ្នាំលោកក៏រាំងរា ព្រោះអីមុនចូលឆ្នាំខ្មែរពីអាទិត្យខ្ញុំក៏បានស្នើលោក វុត្ថា ជិន អតីតប្រធានសមាគមខ្មែរឱ្យគណកម្មការសុំលោកធ្វើបុណ្យចូលឆ្នាំតែលោកមិនព្រមថា "ទុកឱ្យអាត្មាធ្វើបានហើយ"

**សាន សុវិត :** លោកថាមិនបានហាមទេ តែបើតាមលោក គឺមានហាម ខ្ញុំមិនយល់ដែរ ថាព្រះសង្ឃអាចមានវាចារយ៉ាងនេះ ។ លោក គ្រូ យេង តូច បាននិយាយថា មិនបានហាមមិនឱ្យធ្វើបុណ្យចូលឆ្នាំទេ ព្រោះធ្វើបុណ្យខ្លួនឯងតែមិនបាននិយាយឱ្យច្បាស់ "មិនបានហាមគណកម្មាការវត្តមិនឱ្យធ្វើបុណ្យចូលឆ្នាំទេ

**សាន សុវិត :** ឥឡូវការប្តឹងផ្តល់នោះទៅដល់ណាហើយ ?

**គ្រីស្តុហ័រ ង៉ោ :** មិនមានប្តឹងផ្តល់អីទេ តែសុំឱ្យតុលាការចេញបញ្ជាអនុញ្ញាតឱ្យយើងអាចចូលធ្វើការបំរើពុទ្ធបរិស័ទនឹងវត្តអារាមនៅក្នុងទីវត្តវិញបាន ពីយើងជាប់ឆ្នោតត្រូវតែធ្វើការ

**សាន សុវិត :** តើវត្តនេះមានព្រះសង្ឃប៉ុន្មានអង្គ ?

**គ្រីស្តុហ័រ ង៉ោ :** ពីមុនមានលោកតាជាហឿន ជាចៅអធិការវត្ត ឥឡូវសុគតទៅហើយនៅសល់លោកសង្ឃទាំងពីរអង្គមកសុំសំណាក់នោះ ។

***កំណត់និពន្ធ:*** *មកទល់ថ្ងៃនេះ គណកម្មការវត្តនៅតែមិនអាចចូលវត្តបាននៅឡើយ ដោយការប្រើ (អាឡាម) ដែលនឹងហៅប៉ូលិសនៅពេលមានអ្នកក្រៅចូលក្នុងវត្ត ។ ចលនាក្នុងសហគមន៍ឱ្យមានការបោះឆ្នោតជ្រើសរើសគណកម្មការថ្មីមួយទៀតជំនួស គណកម្មការដែលមានជាប់ឆ្នោតរួចទៅហើយ ។ ជម្រៅនៃវិវាទនៅតែស្ថិតនៅវិស័យ "សេដ្ឋកិច្ច"ដែលវត្តសុរិយារង្សីជាប្រភពចំណូលថវិកាដ៏សំខាន់មួយដែលសហព័ន្ធត្រូវការសំរាប់បំរើចលនាតែរករូបមន្តចុះសម្រុងគ្នាប្រកបដោយយុត្តិធម៌មិនទាន់ឃើញ ៕*




# វិស្វកម្មក្នុងចិត្តមនុស្ស
## The human inner engineering



និពន្ធដោយ : ម៉ៅ ច័ន្ទសំណុំ

ការរៀបរាប់ខាងលើនេះជាប្រវត្តិជីវិតលើផែនដីយើងនេះ ។ សូមបញ្ជាក់ថា ពាក្យជីវិតនេះមានន័យម្យ៉ាងទៀត ក្នុងឯកសារសាសនា និងវិទ្យាសាស្ត្រ គេហៅថា កុងស្យនិស (Consciousness) ពាក្យជីវិត និងកុងស្យនិសមានន័យដូចគ្នា ។ មកដល់ពេលនេះ ជីវិតមានអត្ថិភាពគ្រប់កន្លែងគ្រប់ច្រកល្ហក មានតាំងពីសត្វតូចតាចមើលពុំឃើញ មេរោគ អាមិប សីលា រុក្ខជាតិ ត្រី សត្វតូចធំ មនុស្សយើងជាដើម ។ ឯកសារវិទ្យាសាស្ត្រខ្លះបានបង្ហាញថា មនុស្សសត្វ រុក្ខជាតិ មានលក្ខណៈរួមគ្នា ដូចជា សភាវៈបន្តពូជ ការដកដង្ហើម ការប្រើប្រាស់ ចំណីអាហារ ការរីកលូតលាស់ និងការរលំ រលាយ វិនាស បាត់បង់ទៅ ។ ចំណែកឯសត្វ និងមនុស្សមានសភាពដូចជាស្មើរតែគ្រប់ចំណុច ដូចជា មានដងខ្លួន ខួរក្បាល ភ្នែក ច្រមុះ ត្រចៀក អណ្តាត ផ្នែកបន្តពូជ និងពិសេសមានសតិដឹង ។ល។ ដូច្នេះមនុស្សយើងជាផ្នែកមួយនៃធម្មជាតិ ។ មនុស្សយើងទទួលឥទ្ធិពលពីធម្មជាតិដូចសត្វនានាផងដែរ ។ ធម្មជាតិគេបង្កប់ប្រាជ្ញាគ្រប់កន្លែងគេជាវិចិត្រករដ៏ឆ្នើមតុបតែងច្នៃប្រឌិតកសាងជីវិតទាំងអស់លើផែនដីនេះឡើង ។ មើលចុះសត្វត្រីចម្លែកៗក្នុងសមុទ្រសត្វស្លាបប្រកបដោយពណ៌ចំរុះល្អឥតខ្ចោះរុក្ខជាតិប្រកបដោយផ្កាលោមពណ៌គួរឱ្យគយគន់ ។ រោមដែលដុះលើខ្លួនមនុស្សសុទ្ធតែមានភារៈទិសដៅទាំងអស់ ដូចជាសក់ដុះលើក្បាលសំរាប់គ្រប់ដណ្តប់ការពារខួរក្បាលរោមក្លៀកសំរាប់ជួយសំរួលចលនាកកិត ចិញ្ចើម សំរាប់ការពារភ្នែក ។ ចំណែកឯការរំលាយអាហារក្នុងខ្លួនមនុស្សវិញ ក៏មានបែបផែនប្រាកដប្រជាផងដែរ ពេលចំណីចូលទៅក្នុងមាត់ធ្មេញគេមាននាទីបំបែកឱ្យល្អិត ទឹកមាត់មានជាតិគីមីជួយសំរួល លុះអាហារធ្លាក់ដល់ក្នុងក្រពះ ទឹកអ័រម៉ូនគីមីមួយចំនួនលេចចេញមកជួយរំលាយឱ្យចំណីអាហារអាចជ្រាបចូលទៅក្នុងរាងកាយមនុស្សបាន ។ ធម្មជាតិជាវិចិត្រករដ៏មានប្រាជ្ញាអស្ចារ្យណាស់មែនឬទេ? ប្រាជ្ញាពុំមែនឋិតតែក្នុងខួរក្បាលមនុស្សឡើយប្រាជ្ញាមាននៅគ្រប់ទីកន្លែងទាំងអស់លើពិភពលោកនេះ ។

ក្នុងការវិវត្តន៍របស់ធម្មជាតិ រុក្ខជាតិ សត្វ មនុស្ស គេពិនិត្យឃើញដំបូងមានតែ ជីវិត ឬ កុងស្យនិសប៉ុណ្ណោះ ដូចជា អាមិប សីលា រុក្ខជាតិ ជាដើម ។ លុះបន្ទាប់មកគេឃើញមានការលេចឡើងនូវសតិដឹង (Awareness) ម៉េម៉ូរី និងប្រាជ្ញាក្នុងខួរក្បាលលើភពផែនដីនេះ ។ ម៉េម៉ូរីនេះមានន័យថា ការចងចាំ ។

**ចូរពិនិត្យឧទាហរណ៍ខាងក្រោមនេះ :**

សត្វចាបវាមានជីវិត និងមានសតិដឹង ម៉េម៉ូរី ប្រាជ្ញាក៏រិតទៀតផង ។ បើមនុស្សដើរទៅវា ។ វត់គេចភ័យខ្លាចវាចេះធ្វើសំបុកថែរក្សាការពារកូន ។ ប៉ុន្តែប្រាជ្ញា និងម៉េម៉ូរី ទាំងនោះ ឋិតនៅក្នុងក៏រិតទាបក៏រិតសភាវគតិប៉ុណ្ណោះ ។

-សត្វខ្លះដូចជា សត្វធំ វាមានសតិដឹង និងប្រាជ្ញាខ្ពស់ជាងសត្វនានា ឯកសារថ្មីៗបង្ហាញថា សត្វស្វាចេះធ្វើឧបករណ៍នានា សំរាប់ប្រើប្រាស់ចាប់សត្វជាចំណី ។

-សត្វឆ្កែឆ្មា ស្គាល់ម្ចាស់ ហើយមនុស្សអាចបង្ហាត់វាទៀតផង ។

-សត្វខ្លា តោ ដំរី ពួកគេរួមរស់ជាក្រុមសម្ព័ន្ធមានមេកើយគ្រប់គ្រង ។ វីដេអូ ទំនើបបានបង្ហាញអំពីការប្រើអំណាចក្នុងពិភពសត្វគៀបសង្កត់គូប្រឆាំងការថែរក្សាកូនចៅ ការថ្នាក់ថ្នមស្នេហ៍ ការភ័យខ្លាច ការព្រួយបារម្ភ ការសប្បាយរីករាយ ការចូលរួមមរណទុក្ខ លោភលន់ កំហឹង ។ល។ ក្នុងពិភពសត្វ នរណា ខ្លាំងអ្នកនោះឈ្នះ ត្រីធំត្រីតូច ក្រពើស៊ីគោព្រៃ ខ្លាស៊ីប្រើស តោស៊ីកូនខ្លួនឯង ។

**មនុស្សជាសត្វលោកដែលវិវត្តខ្ពស់ជាងគេបំផុត**

លុះជីវិតដែលបានវិវត្តន៍ពីសត្វមកមនុស្ស គេពិនិត្យឃើញលេចឡើងនូវចំណុចកត់សម្គាល់ដូចខាងក្រោមនេះ :

**១-**មនុស្សនៅផ្ទុកដោយធាតុសត្វ ចំហាយសត្វ មួយចំណែកធំ កប់ក្នុងប្រពន្ធ័រូបកាយ និងចិត្តមនុស្ស ដូចជា ភាពកាចសាហាវ កំរោល ពុំយោគយល់ លោភលន់ កំហឹង អំណាច ធាតុ យក្សធាតុតិរិច្ឆាន ដូចមានពិពណ៌នា ក្នុងអត្ថបទព្រះពុទ្ធសាសនា ដែកពោលទុកមកថា មានមនុស្សទេវៅ គឺមនុស្សជាមនុស្សទេវតា -មនុស្ស : មនុស្សោ គឺជាមនុស្សយើងនេះ -មនុស្សតិរិច្ឆានណា គឺជាមនុស្សតិរិច្ឆាន -មនុស្សប្រេតោ គឺជាមនុស្សប្រេតុនរក ។

២-ខួរក្បាលមនុស្សវិតវត្តឡើងខ្ពស់ជាងសត្វ ។ មនុស្សមានសតិ និងម៉េម៉ូរី ប្រាជ្ញា ដែលកាន់តែសុក្រិតឡើងៗ នោះគឺជាដំណើរនិន្នាការវិវត្តន៍ខ្ពស់ឡើង ក្នុងពិភពជីវិតលើភពផែនដីនេះ ។

**តទៅលេខក្រោយ**







# ក្រុមប្រឹក្សាវប្បធម៌ខ្មែរ

KHMER CULTURAL COUNCIL

## លិខិតថ្លែងអំណរគុណ

### គណៈកម្មាធិការក្រុមប្រឹក្សាវប្បធម៌ខ្មែរ

សូមថ្លែងអំណរអរព្រះគុណ និង អរគុណយ៉ាងជ្រាលជ្រៅ ដល់ព្រះតេជគុណគ្រប់ព្រះអង្គ ជាពិសេសលោកតា.លោកយាយ.អ៊ុំប្រុស .អ៊ុំស្រី លោកពូ អ្នកមីង បងប្អូនរួមជាតិខ្មែរយើងទាំងអស់ បានលះបង់កំលាំងកាយ ពេលវេលា មោងធ្វើការងារចិញ្ចឹមជីវិតផ្ទាល់ខ្លួន រួមជាមួយការឧបត្ថម្ភថវិការ កន្លងមក ដើម្បីបំរើកិច្ចការសង្គម ក្នុងមូលហេតុ រក្សារនិងការពារព្រះពុទ្ធសាសនាខ្មែរ មិនអោយមនុស្សអគតិមកបំភាន់ភ្នែក បងប្អូនរួមជាតិខ្មែរ ដើរប្រព្រិត្តអំពើមិនគប្បី មិនគោរពវិន័យព្រះសង្ឃយកទីវត្តអារាម ដែលប្រជាជនតែងតែគោរពមកជាន់ឈ្លី ហើយឃោសនា បោកប្រាស់យកជាផលប្រយោជន៍ផ្ទាល់ខ្លួនផ្សេង ៗ ។ល។

គណៈកម្មាធិការក្រុមប្រឹក្សាវប្បធម៌ខ្មែរយើងខ្ញុំនិងចងចាំមិនភ្លេចនូវការជួយជ្រោមជ្រែងនិងជួយឧបត្ថម្ភកន្លងមក យើងខ្ញុំនូវតែសង្ឃឹមជឿរជាក់ថាបងប្អូនរួមជាតិខ្មែរយើងទាំងអស់ បន្តរសកម្មភាពគាំទ្រតទៅទៀត រហូតដល់បានសំរេចជោគជ័យជាស្ថាបពរ ក្នុងពេលដ៏ខ្លីខាងមុខនេះ ។

សូមមេត្តាទទួលនូវការគោរព រាប់អានយ៉ាងជ្រាលជ្រៅ និង សូមទេវតាឆ្នាំថ្មី ជួយថែរក្សា បងប្អូនរួមជាតិខ្មែរយើងទាំងអស់ ជួបតែសេចក្តីសុខ ក្សេមក្សាន្តជាជារៀងរហូតតទៅ កុំបីខានឡើយ ។

ធ្វើនៅទីក្រុងឡូវែល. ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៣

ជ.គណៈកម្មាធិការក្រុមប្រឹក្សាវប្បធម៌ខ្មែរ

Sithy




# ហាងខ្មែរជួសជុលរថយន្ត

**បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ**

# Rathe´s Auto Service

State and Emission
Inspaction General
Repairs and Maintenance




MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកីរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្តាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

# ក្រុមហ៊ុនទេសចរណ៍

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុងនិងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ធ្វើទិដ្ឋាការសំរាប់ទេសចរណ៍
- ធ្វើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

CENTURY TRAVEL & SERVICE CENTER
**904 South 8th Street. Philadelphia, PA 19147**
**Tel : 215-625-2889; Cell : 267-934-9888**

# ខ្មែរជួសជុលរថយន្ត

# KHMER AUTO REPAIR

**CAR INSPECTION, DIAGNOTIC & REPAIR**

**ត្រួតពិនិត្យរថយន្តបញ្ជារដ្ឋ**
- ឆែករកកន្លែងខូចខាត និងជួសជុល
- យើងធ្វើហ្វ្រាំង ឬប្រេក
- ត្រួតពិនិត្យធ្វើម៉ាស៊ីនឱ្យស្រួលឡើងវិញ
- បញ្ចេះឡានអាល់ទេណាទ័រ
- បូមចរន្តទឹកវេឌីណាទ័រ
- សេវាត្រង់បីស្សង
- មើលតម្រងទ្រនាប់ និងពីញូង

Brake Service
Turn up electronic
Starters Alternators
Radiators water pumps
Transmission Service
Struts checked & serviced
CV Joints Rack & Pinion
Shocks checked & Replace

115 West. Tabor Rd, Philadelphia, PA 19120
Tel: (215) 455-1422/Pat: 215-939-5634

# ជោគជតារាសីទាំង 12 ប្រចាំឆ្នាំហោង

ជោគជតាប្រចាំសប្តាហ៍

### ឆ្នាំជូត

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិនិងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើ តែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

### ឆ្នាំថោះ

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះសូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

### ឆ្នាំមមី

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្ដីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្អុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្សតាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

### ឆ្នាំរកា

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះ សុទ្ធតែផ្ដល់នូវអត្ថប្រយោជន៍គួរឱ្យជាទីពេញចិត្តទាំងអស់គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវករ រកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នាបើនៅឆ្ងាយ ៕

### ឆ្នាំឆ្លូវ

អាចពោលបានថា លោកអ្នកមានសេចក្ដីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរនៅទីណាក្ដីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

### ឆ្នាំរោង

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

### ឆ្នាំមមែ

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្ដាប់ឱវាទគ្នា ៕

### ឆ្នាំច

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗនាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់ បើអាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

### ឆ្នាំខាល

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះ វាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហាពុំមានផលរមាស់អ្វីនោះឡើយ ៕

### ឆ្នាំម្សាញ់

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

### ឆ្នាំវក

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរើងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបានដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

### ឆ្នាំកុរ

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមកហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណងហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហា គូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕


## ក្រុមហ៊ុនធានារ៉ាប់រងដែលបាន បំរើសង្គម២២ឆ្នាំហើយ

## CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

www.ConwayInsurance.com

សូមសួររក Philip Muth, Philip@ConwayInsurance.com

## East Coast Center

for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឱ្យធំ កែខ្នង់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

តមកទំព័រទី ១
## ជំលោះបងប្អូនរួមឈាមវត្តសុរិយារង្សី...

កុំភ្លេចខ្លួនឱ្យសោះថា យើងទាំងអស់គ្នាមានបំណុលត្រូវតែសងចំពោះទឹកដីមាតុភូមិដែលបានបង្កើតយើងខំរៀន បេះចោលនូវ ចរិកប្រកាន់ខុសទំនង,” ចរិកមើលឃើញតែកំហុសគេអញត្រូវរហូត! ។ បើចោលតែម្តងមិនបានសុំខំបេះចោលម្តងបន្តិចចូររៀនបិទភ្នែកសម្លឹងមើលមកខ្លួនឯងម្តងសម្លឹងមើលទៅគេតាំងពីចេញពីផ្ទៃម្តាយយំអេះង៉ាអេះង៉ាមកម្លេះ។ ទាំងអស់គ្នាយើងជាអ្នកចោលស្រុកចូរខំសំឡឹងមកខ្លួនឯងម្តង តើយើងបានធ្វើអីល្អពិតប្រាកដសម្រាប់ស្រុកភូមិយើង, ចូរខំកសាងធ្វើឱ្យសហគមន៏នៃខ្លួនដោយស្មោះត្រង់បំផុត,ត្រូវស្គាល់កំហុសខ្លួនឯងជាចាំបាច់,បើពុំដូច្នោះទេ យើងមិអាចកសាងសង្គមមួយសុខសាន្តបានទេ។ យើងគ្មានមេដឹកនាំណាម្នាក់ទទួលស្គាល់កំហុសខ្លួនឯងទាល់តែសោះក្នុងប្រវត្តិសាស្ត្រ។ រឿងនេះហើយដែលធ្វើឱ្យខ្មែររងកម្មមិនឈប់ ព្រោះមេដឹកនាំរបស់យើងចចេសយកត្រូវតែខ្លួនឯងនេះ។

រឿងវិវាទបងប្អូនរួមឈាមនៅវត្តសុរិយារង្សីវាក៏នៅត្រង់បងប្អូនយើងទាំងអស់គ្នាមិនព្រមសម្លឹងមកខ្លួនឯងសោះចេះតែសម្លឹងទៅរកកំហុសនៃដៃគូវិវាទរបស់ខ្លួនចេះតែគិតថា ខ្លួនឯងគ្មានកំហុសសោះដៃគូរបស់ខ្លួនទេដែលមានកំហុសដៃគូរបស់ខ្លួនទេដែលត្រូវតែកែប្រែ,ខ្លួនឯងអត់មានអីត្រូវកែប្រែទាល់តែសោះ,បើស្តាប់ទៅដូចសុទ្ធតែជាអ្នកស្រឡាញ់ជាតិសាសនា,សង្គមដូចៗគ្នា,ចង់ជួយឱ្យសហគមន៏លូតលាស់ចំរើនរុងរឿងដូចៗគ្នាតែឆ្ងល់ថាហេតុអីមិនព្រមជួបមុខគ្នានិយាយគ្នាក្នុងភាពជាបងប្អូន?ចេះតែមានកលល្បិចកិច្ចកល់តែរៀងៗខ្លួន? នេះគេហៅថា ល្បិចយកចំណេញខាងនយោបាយនោះអី? អ្នកអានចេះតែចង់ដឹង, ចង់សង្ឃឹមថា គូវិវាទទាំងសង្ខាងប្រហែលជាត្រូវរ៉ូវស្រុះស្រួលគ្នាល្អហើយមើលទៅ ព្រោះយើងទាំងសង្ខាងសុទ្ធតែជាអ្នករងទុក្ខគ្រប់គ្រាន់ ហើយបណ្តាលមកពីការបាក់បែកប្រេះឆានៃអ្នកដឹកនាំរបស់យើង,របស់អ្នកដែលរស់មុនជំនាន់យើងប្រហែលពួកយើងទទួលបានមេរៀននេះ,ចេះកែប្រែហើយទេដឹង? សុំឆ្លើយថាទេ!!! គ្មានសោះ, ចរិកខ្មែររបស់បងប្អូនយើងនៅតែដដែល!!! ។ចង់ឈ្នះចង់ចាញ់បងប្អូនឯងប្តឹងប្តល់ឱ្យឈ្នះបានដីមួយកំពកសុខចិត្តលក់ដីមួយរយហាត់តាយកធ្វើសាហ៊ុយ...សុខចិត្តបាត់ដីទៅសៀមអស់ជាងម្តេខេត្តឱ្យតែអញឈ្នះ, ជាងម្តៃខេត្តទៀតបានទៅយួនក៏អញមិនខ្វល់ឱ្យតែអញឈ្នះលទ្ធផលជាក់ស្តែងនៃប្រវត្តិសាស្ត្រដ៏ចុកឈាមនេះបងប្អូនបានឃើញឬទេ? ចាំឬទេ? បើបងប្អូនម្ខាងណាឈ្នះបានវត្តមកក្រុំខ្លួនកាន់កាប់ តើវាកិត្តិយសស្អីទៅ, អ្នកក្លាហានអីទៅក្នុងជោគជ័យដណ្តើមបានជ័យភ័ននេះ បើបាត់អស់បងប្អូនរួមឈាមឯងជាងពាក់កណ្តាលបែកចាកចេញទៅទាំងក្តៅក្រហាយទាំងស្តាយកំហឹងទៅតាមផង? គ្រួសារខ្លះម្តាយឪពុកកាន់ជើងក្រុំម្ខាង, កូនចៅចូលខាងក្រុំម្ខាងគ្រួសារទាំងនេះ ក៏ត្រូវបែកបាក់រាត់រាយអស់ដោយសារតែជោគជ័យគ្មានកិត្តិយសរៀងៗខ្លួននៃបងប្អូនទាំងពីរក្រុំ។ គួរតាំងចិត្តឱ្យបរិសុទ្ធទាំងសង្ខាងលំឱនទៅរកគ្នាដោយអរិយ៏សទ្ធាជ្រះថ្លាបំផុត...មានតែអ្នកទាំងសង្ខាងនេះទេដែលយល់ខ្លួនឯងច្បាស់ជាងគេថា ខ្លួនមានកំហុសកន្លែងណាគួរកែប្រែក្រុំបញ្ញសីលាបានស្តាប់ទាំងសង្ខាងបានពិចារណាល្អិតល្អន់ ហើយបានឃើញថា មានកំហុសទាំងសង្ខាងតែខ្លួនឯងនៅតែចចេសមិនព្រមទទួលស្គាល់, ឃើញតែកំហុសរបស់ដៃគូរបស់ខ្លួន។ដើម្បីបញ្ចប់ក្តីវិវាទនេះមានតែតុលាការទេ គេមានអំណាចបង្ខំឱ្យគូវិវាទទាំងសង្ខាងទទួលយកនូវកំហុសរៀងៗខ្លួនបាន។ អ្នកខំសរសេរអត្ថបទនេះនៅតែមានសង្ឃឹមថា គូវិវាទទាំងសង្ខាងគង់តែទុកពេលបន្តិចបន្តួចពិចារណារឿងនេះឡើងវិញមិនខានចូរចាំក្នុងចិត្តថា កុំឱ្យឈ្នះបានដីមួយកំពកហើយខំលក់ដី១០០ហាត់តាឱ្យសោះឈ្នះបានជ័យភ័នទាំងស្រុងតែបាត់អ្នកមានឈាមជ័រដូចខ្លួនដែលធ្លាប់ការពារខ្លួនអស់ពេលដ៏យូរត្រូវស្តាយកំហឹងវេចបង្វិចចាកចេញទៅ តើបងប្អូនស្បាយនឹងជ័យជំនះនឹងជ័យភ័ននេះកើតដែរឬ? ពិបាកអីនឹងការលំឱនទៅរកគ្នាដោយស្មោះក្នុងស្មារតីធ្វើពលិកម្មដើម្បីជនរួមឈាមរបស់ខ្លួន? ដើម្បីកិត្តិយសរួមក្នុងការមូលត្រកូលយ៉ាងសុខដុំរមនានេះ? បើនៅតែមិនព្រមលំឱនដោយស្មោះទេ,សុំបងប្អូនចេះតែប្តឹងគ្នាទៀតចុះ, ចូរខំទ្រាំរង់ចាំជោគជ័យរៀងៗខ្លួនចុះយើងខ្ញុំទាំងអស់គ្នាដែលមិនចូល ឬមិនកាន់ជើងបក្ខពួកខាណាតែជាក្រុំពុទ្ធបរិស័ទជើងវត្តសុរិយារង្សីបានចេញលុយកាក់កសាងវត្តដែរនោះ សូមសំណូមពរម្យាងគត់គឺក្រុំនិមួយៗនៃដៃគូវិវាទមេត្តាចេញលុយផ្ទាល់ខ្លួនរៀងៗខ្លួនទៅគិតគូរជាមួយ ”អារោកា” ដើម្បីកិត្តិយសគ្មានន័យតែរៀងៗខ្លួនទៅចុះសូមកុំយកសប្បត្តិរួមកេរ្តិ៍អាករួមដើម្បីការក្តីក្តាំដ៏គ្មានន័យនេះឱ្យសោះ ៕

**អរគុណ**

តមកទំព័រទី ៧
## សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហម...

សរសើរគណបក្សប្រជាជនកម្ពុជាយ៉ាងខ្លាំង ។

ទោះបីជាលោក ជុំ ម៉ី បានបដិសេធជាច្រើនលើកច្រើនសារថា មិនមានការគាំទ្រពីរដ្ឋាភិបាលចំពោះការតវ៉ារបស់លោក និងបានអះអាងថាលោកធ្វើសកម្មភាពក្នុងឋានៈជាពលរដ្ឋក៏ដោយក៏សមាគមជនរងគ្រោះនេះ គិតថា សកម្មភាពរបស់លោក ជុំម៉ី ធ្វើឱ្យសមាគមនេះលែងមានការទុកចិត្តគ្នាដែរ។

លោក ប៊ូ ម៉េង អ្នករួចជីវិតម្នាក់ទៀតពីគុកទួលស្លែង និងជាអនុប្រធានទី២នៃសមាគមនេះថ្លែងកាលពីម្សិលមិញថា សមាគមនឹងបើកមហាសន្និបាតបន្ទាប់ពីការបោះឆ្នោត ប៉ុន្តែបានបដិសេធមិនប្រាប់ពីមូលហេតុនោះទេ ។

លោកបានមានប្រសាសន៏ថា សមាគមរបស់យើងកំពុងមានបញ្ហាស្មុគស្មាញមួយ ។ យើងមិនចង់ធ្វើអ្វីទេអំឡុងពេលបោះឆ្នោត” ។

លោក ជុំ ម៉ី បានមានប្រសាសន៏ថា ”យើងនឹងចុះចេញដោយគ្មានការតវ៉ាឡើយ ប្រសិនបើគេបោះឆ្នោតដកខ្ញុំនោះ” ប៉ុន្តែបានមានប្រសាសន៏កាលពីម្សិលមិញថា លោកនឹងមិនលាឈប់ជាមុននោះទេ ។

លោក ជុំ ម៉ី បានមានប្រសាសន៏ថា ”វាអាស្រ័យលើសមាជិកភាគច្រើនរបស់សមាគមនេះក្នុងការបោះឆ្នោតជ្រើសរើសនរណាម្នាក់ឱ្យធ្វើជាប្រធាន” ៕

*ប្រែសម្រួលដោយ ស៊ីំសុខភ្នំ*


Golden Video Shop Providence

មានលក់ថាសចម្រៀង និងខ្សែវីដេអូ-ខ្មែរ-ចិន-ថៃ (401)-808-9336

VM LAPTOPS CENTER

- VANNAK MOEUN (Manager)

មានជួសជុល-ទិញ និងលក់”ឡាប់តុប” គ្រប់យ៉ាង

**301 Reservoie Ave. Providence RI 02907**

**ប្រូវិជិនខ្មែរវីដេអូ**

មានជួលនិងលក់កុនចិន-ថៃ-ខ្មែរ-ឥណ្ឌាគ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ ខារ៉ាអូខេថ្មីៗ

742 Pottess Avenue

Providence, RI 02907 ទូរស័ព្ទ : **(401) 787 6663**

**ផ្ទះសំរាប់ជួល**

-ផ្ទះ Single House នៅ Chelmsford Mass ជិតមណ្ឌលពាណិជ្ជកម្ម មានបីបន្ទប់គេង បន្ទប់ទទួលភ្ញៀវ បន្ទប់បាយ បន្ទប់បោកខោអាវ មានផ្លូវចូលធំ មានទទួល Section 8

-មាន ២បន្ទប់គេង នៅក្បែរផ្សារបាត់ដំបង សំរាប់ជួលដែរ

ទូរស័ព្ទ : **(978) 967-6695**

**(978) 987-3766**

**លក់ហាងប្រ្វហ្សិនយ៉ូហ្គឺត**

ឪកាសក្លាយជាម្ចាស់ខ្ញុំហាងប្រ្វហ្សិនយ៉ូហ្គឺត។ ហាងទើបតែចាប់ផ្តើមបើកថ្មីៗនៅវីលម៉ីងតុង (Wilnington)។ យើងត្រូវការលក់ហាងនេះ ។ គ្មានបទពិសោធន៏ជំនួញនេះក៏អាចធ្វើបានដែរ ហើយងាយស្រួលរៀបចំថែមទៀត ។ ថ្លៃលក់ហាងថោកជាងថ្លៃដែលបានចំណាយសាងសង់ហាង ។

ថ្លៃលក់ហាង : **$200,000**

ប្រាក់ចំណូលអាចរកបាន : **$10,000** ឬច្រើនជាងនេះ ។

សូមហៅមកកាន់ : **978-967-6695**

**ហាងសំរាប់ជួល**

295-Westford St., Lowell,MA

អាចបើកជាភោជនីយដ្ឋាន ឬហាងកែសម្ផស្ស ឬហាងលក់ចាប់ហួយ

សូមហៅមកកាន់ : **791-391-2931**

ដើម្បីទទួលបានព័ត៌មានបន្ថែម

**ការិយាល័យ មេធាវី**

**ថំមាស ស្តាលីយ៉ាណូស**

**Law Office of Thomas Stylianos Jr.**

**287 Appleton St. Lowell MA 01852**

Immigration • Divorce • Auto Crash

▸ អន្តោប្រវេសន៏ ▸ គ្រោះថ្នាក់រថយន្ត ▸ លែងលះប្តីប្រពន្ធ

Call: Sophea or Thomas សូមទូរស័ព្ទមក: សោភា ឬថំ

**978-459-5000 or 800-308-3766**

Only Licensed in Massachusets

# AccuCare Homecare Agency

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



Compassionate Care & Reliable
Professional & Cultural Sensitive
Management & Staffs speak Khmer

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារ៉ាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។

Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.

## ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

To be eligibled for GAFC you must:

- រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)
- អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)
- មានសំបុត្រសុខភាពរដ្ឋ (eligible for Masshealth Standard)
- ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)
- មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអ្នក (have physician statement of your condition)
- ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )

## ផលប្រយោជន៍ទទួលបាន :

Benefits you will get:

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ (an individual care plan developed by a registered nurse and case manager)
- វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)
- សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:



អ៊ុក តុលាយុទ្ធ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



ពិន ឆាវ៉ាន់ លីន រីវៀរ បូស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200. Allston, MA 02134



"នាងប្រាប់ខ្ញុំគ្រប់យ៉ាង

# ខ្ញុំសប្បាយចិត្តខ្លាំងណាស់។

នាងពេញចិត្តនៅផ្ទះជាមួយយើង។"



CAREGIVER™ HOMES

Caregiver Homes™ ជួយចាស់ជរា
និងជនពិការឱ្យរីករាយជាមួយ
នឹងគុណភាពខ្ពស់នៃជីវិតនៅផ្ទះ

- បង់ប្រាក់ & បង្រៀនបណ្ដុះបណ្ដាល អ្នកថែទាំពេញពេលដែលរស់នៅជាមួយ
- ផ្ដល់ជំនួយ ប្រកបដោយវិជ្ជាជីវៈ ពីគិលានុបដ្ឋាយិកា និង អ្នកថែទាំ ដែលចេះយកចិត្តទុកដាក់
- ជួយអ្នកស្វែងរក & ទទួលបានគ្រប់សេវាដែលចាំបាច់

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **866.797.2333** ឬចូលមកគេហទំព័ររបស់យើង។

**WWW.CAREGIVERHOMES.COM**


ប្រើធនាគារឲ្យប្រសើរ
គឺនៅក្នុងកាបូប
FREE
$150 gift card to Coach®
កាតរង្វាន់$150ទិញកាបូបល្បីឈ្មោះ"ខូច"
ជាមួយការបើកសេវាសម្រាប់ប្រើធនាគាររាល់ថ្ងៃ
Washington SAVINGS BANK
washingtonsavings.com
* Restrictions apply Ask for details.
Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate" and implementing the following combination of new services after 12/10/2012: A monthly direct deposit of at least $1,000 from an unaffiliated third party, at least one monthly automatic withdrawal that is not web or card based and an active debit card with 12 or more completed purchases is eligible for a $150 Coach® gift certificate. Promotion ends 06/30/2013. Coach® is a trademark of Coach, Inc. The program is not endorsed by Coach, Inc. nor is there any actual or implied joint venture, partnership or relationship of any kind between Washington Savings Bank and Coach, Inc. Promotions cannot be combined, one gift per customer, per account, per household. Available to personal accounts only. Fee of $150 applies for account closure or change of services within 6 months of free gift receipt. Washington Savings Bank reserves the right to disqualify any account/ person from this promotion if, in its sole discretion, it determines the account and/or services are solely designed to qualify for the free gift. Limited time offer, while supplies last.